ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរកសិកម្ម ខេត្តកំពង់ស្ពឺ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយក្នុងវិស័យកសិកម្ម នៅខេត្តកំពង់ស្ពឺ ២០១៤ - ២០១៨

ខែ មីនា ឆ្នាំ ២០១៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

មន្ទីរកសិកម្ម ខេត្តកំពង់ស្ពឺ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយក្នុងវិស័យកសិកម្ម នៅខេត្តកំពង់ស្ពឺ

## ២០១៤ - ២០១៨

Humanitarian Aid
and Civil Protection

ឯកសារនេះ ត្រូវបានផលិតឡើង ក្រោមជំនួយហិរញ្ញវត្ថុពីអគ្គនាយកដ្ឋាននៃគណៈកម្មការសហគមន៍អឺរ៉ុប សម្រាប់ជំនួយមនុស្សធម៌និងកិច្ចគាំពារជនស៊ីវិល និងក្រោមជំនួយបច្ចេកទេសពីអង្គការស្បៀងនិងកសិកម្ម នៃសហប្រជាជាតិប្រចាំកម្ពុជា។ រាល់ទស្សនៈទាំងឡាយក្នុងអត្ថបទនេះ មិនត្រូវបានឆ្លុះបញ្ចាំងពីទស្សនៈរបស់សហគមន៍អឺរ៉ុប និង ឬ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឡើយ។

រាល់ការផលិតឯកសារនេះឡើងវិញ ដោយផ្នែក ឬទាំងមូល សម្រាប់ការបង្កើនការយល់ដឹង ការកសាងផែនការក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណូលនានាត្រូវបានអនុញ្ញាត ដោយគ្រាន់តែទាមទារនូវការទទួលស្គាល់ប្រភពនៃអ្នករៀបចំព័ត៌មាន។ រាល់ការផលិតឯកសារនេះឡើងវិញ ក្នុងគោលបំណងស្វែងរកប្រាក់ចំណេញត្រូវបានហាមឃាត់ដោយមិនបានសុំការអនុញ្ញាតិពីអ្នកផលិត។

This document has been produced with the financial assistance of the European Commission's Humanitarian Aid and Civil Protection (ECHO) and with technical assistance of Food and Agriculture Organization of the United Nations (FAO). The views expressed herein should not be taken, in any way, to reflect the official opinion of the European Commission and or FAO.

Reproduction of any part of this publication for awareness raising, planning, and any other non-profit purpose is authorized without prior permission from the publisher, provided that the source is fully acknowledged. Reproduction for resale or other commercial purpose is prohibited without prior written permission from the publisher.

# អារម្ភកថា

ផលិតផលកសិកម្ម និងមុខរបររបស់កសិករមួយចំនួននៅក្នុងខេត្ត តែងតែទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ។ កសិករក្រីក្រមានភាពងាយរងគ្រោះយ៉ាងខ្លាំង ដោយសារការប្រឈមទៅនឹងមុខសញ្ញាគ្រោះថ្នាក់មានកម្រិតខ្ពស់ ការអនុវត្តកសិកម្មឯកវប្បកម្ម កសិកម្មអាស្រ័យរបបទឹកភ្លៀង និងទិន្នផលកសិកម្មទាប។ ការប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ដែលមានកម្រិតខ្ពស់ គួបផ្សំជាមួយទិន្នផលទាបនៃផលិតកម្ម បានគំរាមកំហែងទៅដល់សុវត្ថិភាពនៃប្រព័ន្ធមុខរបររបស់គ្រួសារកសិករក្រីក្រ បង្កការខូចខាត និងបាត់បង់ដល់ទ្រព្យសម្បត្តិនិងអាយុជីវិត ជាពិសេសនៅក្នុងកំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយ។

មន្ទីរកិសកម្មខេត្តកំពង់ស្ពឺ មានការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋទាំងនោះ និងសហគមន៍ដែលអាស្រ័យផលលើវិស័យកសិកម្ម និងបង្កើនសមត្ថភាពដល់ស្ថាប័នជំនាញ និងសហគមន៍កសិកម្ម ដើម្បីកាត់បន្ថយការខូចខាត និងការបាត់បង់ ព្រមទាំងកាត់បន្ថយការលំបាករបស់កសិករ និងសហគមន៍ដែលអាស្រ័យផលលើវិស័យកសិកម្ម។ មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ បានសម្របសម្រួលការរៀបចំផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្មក្នុងខេត្តកំពង់ស្ពឺ ២០១៤-២០១៨។ ផែនការនេះត្រូវបានរៀបចំឡើងជាផែនទីបង្ហាញផ្លូវ ដែលរួមបញ្ចូលចំណុចសំខាន់ៗ នៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងវិស័យកសិកម្ម ពិសេសសម្រាប់ផលិតកម្មដំណាំនិងផលិតកម្មសត្វ។ ផែនការនេះនឹងជួយចូលរួមចំណែកក្នុងការអនុវត្តផែនការសកម្មភាព សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្មថ្នាក់ជាតិ របស់អគ្គនាយកដ្ឋានកសិកម្ម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣។

ការកសាងផែនការសកម្មភាពនេះ មានការចូលរួមយ៉ាងសកម្មពីគ្រប់ការិយាល័យជំនាញរបស់មន្ទីរកសិកម្មខេត្ត មន្ទីរពាក់ព័ន្ធជុំវិញខេត្ត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងខេត្តកំពង់ស្ពឺ។ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ បានផ្តល់ជំនួយបច្ចេកទេស សម្រាប់ការកសាងផែនការសកម្មភាពនេះ ក្រោមជំនួយហិរញ្ញវត្ថុពីអគ្គនាយកដ្ឋាននៃគណៈកម្មការសហគមន៍អឺរ៉ុបសម្រាប់ជំនួយមនុស្សធម៌ និងកិច្ចគាំពារជនស៊ីវិល។

**ប្រធានមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ**

**សយ បញ្ញា**

# សេចក្តីថ្លែងអំណរគុណ

ផែនការសកម្មភាព សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយលើវិស័យកសិកម្ម នៅខេត្តកំពង់ស្ពឺ ត្រូវបានរៀបចំឡើង ក្រោមមូលដ្ឋាននៃដំណើរការប្រឹក្សាយោបល់ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធលើផ្នែកកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ មន្ទីរធនធានទឹកនិងឧតុនិយមខេត្ត មន្ទីរជុំវិញខេត្ត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងដៃគូអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម។ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិប្រចាំប្រទេសកម្ពុជា បានជួយសម្របសម្រួលដល់ដំណើររៀបចំផែនការនេះ ក្រោមគម្រោង "ពង្រឹងសមត្ថភាពក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្មនៅប្រទេសកម្ពុជា និង ហ្វីលីពីន" និងដោយមានការឧបត្ថម្ភហិរញ្ញវត្ថុពីអគ្គនាយកដ្ឋាននៃគណៈកម្មការសហគមន៍អឺរ៉ុបសម្រាប់ជំនួយមនុស្សធម៌ និងកិច្ចគាំពារជនស៊ីវិល។

សូមអរគុណចំពោះ លោក ទៀង ហ៊ីល្លីណា លោក ជិន អឿង លោកស្រី ជា ដានី និងលោក ជា ហុកលី សម្រាប់ការរៀបចំ និងការជួយគាំទ្រក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ព្រមទាំងសិក្ខាសាលាស្តីពីការត្រួតពិនិត្យបច្ចេកទេស សម្រាប់ធាតុចូលបច្ចេកទេស និងការត្រួតពិនិត្យកែសម្រួលឡើងវិញលើផែនការសកម្មភាពនេះ។

សូមថ្លែងអំណរគុណចំពោះ លោកប្រធាន-អនុប្រធានការិយាល័យជំនាញ ប្រធានការិយាល័យកសិកម្មស្រុកនៃមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ តំណាងរបស់មន្ទីរជុំវិញខេត្ត និងតំណាងអង្គការមិនមែនរដ្ឋាភិបាល សម្រាប់ធាតុចូលបច្ចេកទេសក្នុងការកសាងផែនការសកម្មភាពនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្ឌិត ស្តេហ្វាន បាសស៍ ដែលបានផ្តល់នូវការណែនាំ និងសម្របសម្រួលសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។ សូមថ្លែងអំណរគុណចំពោះលោក ឡឹក សុធារ សម្រាប់ការរៀបចំ ការត្រួតពិនិត្យលើផ្នែកបច្ចេកទេសជារួម និងការចងក្រងផែនការសកម្មភាពនេះ។

សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម ប៉ុន ណារិទ្ធ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សម្រាប់ការត្រួតពិនិត្យលើវាក្យស័ព្ទ និងខ្លឹមសារបច្ចេកទេស និងផ្តល់នូវអំណានផែនការសកម្មភាពជាខេមរភាសា។

# សេចក្តីសង្ខេប

ខេត្តកំពង់ស្ពឺតែងតែជួបប្រទះនូវផលប៉ះពាល់ពីគ្រោះមហន្តរាយធម្មជាតិ ដូចជាគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ សមាសភាគចង្រៃនិងជំងឺ និងខ្យល់កន្ត្រាក់។ គ្រោះមហន្តរាយទាំងនេះបានបង្កឲ្យមានការខូចខាត បាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ ប៉ះពាល់ដល់កម្រិតជីវភាព និងរារាំងដល់ដំណើរការអភិវឌ្ឍន៍ ដែលចាំបាច់ត្រូវបង្វែរមូលនិធិសម្រាប់ការអភិវឌ្ឍន៍ទៅជួយគ្រោះមហន្តរាយវិញ។ ថវិកាជាច្រើនលានដុល្លាត្រូវបានប្រើប្រាស់សម្រាប់សង្គ្រោះអាយុជីវិត និងការស្តារឡើងវិញកម្រិតជីវភាពរបស់ប្រជាជន។

ដើម្បីត្រៀមរៀបចំឲ្យកាន់តែល្អប្រសើរសម្រាប់ផលប៉ះពាល់ទាំងនេះ មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ដោយមានការគាំទ្របច្ចេកទេសពីអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា បានសម្របសម្រួលរៀបចំផែនការសកម្មភាព សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម ដែលមានរយៈពេលប្រាំឆ្នាំ ២០១៤-២០១៨។ អគ្គនាយកដ្ឋាននៃគណៈកម្មការសហគមន៍អឺរ៉ុបសម្រាប់ជំនួយមនុស្សធម៌ និងកិច្ចគាំពារជនស៊ីវិល ផ្តល់ការគាំទ្រហិរញ្ញវត្ថុសម្រាប់ការកសាងផែនការសកម្ម ភាពនេះ។

ផែនការសកម្មភាពនេះត្រូវបានរៀបចំជាឯកសារណែនាំជាក់ស្តែង និងជាផែនទីបង្ហាញផ្លូវដើម្បីគាំទ្រគោលគំនិតគន្លឹះនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម ពិសេសផលិតកម្មដំណាំ និងផលិតកម្មសត្វ និងដើម្បីបញ្ជូលគោលគំនិតគន្លឹះទាំងនោះ ទៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ផែនការនេះក៏ស្វែងរកការរួបរួមធនធាន និងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយឫសគល់នៃបញ្ហាចំពោះការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (CCA) នៅក្នុងវិស័យកសិកម្មផងដែរ។

ផែនការសកម្មភាពនេះរួមមាន៤ជំពូក។ ជំពូកទី១ គឺជាសេចក្តីផ្តើម ដែលរៀបរាប់អំពីស្ថានភាពភូមិសាស្ត្រខេត្តកំពង់ស្ពឺ តម្រូវការនៃការកសាងផែនការសកម្មភាពតាមវិស័យ វិសាលភាព និងគោលការណ៍ណែនាំ ព្រមទាំងដំណើរការនៃការកសាងផែនការ។ ជំពូកទី២ ពិភាក្សាពីមុខសញ្ញាគ្រោះថ្នាក់សំខាន់ៗដែលបង្កឲ្យមានផលប៉ះពាល់ជាសក្តានុពលដល់វិស័យកសិកម្ម និង រៀបរាប់អំពីក្របខ័ណ្ឌគោលនយោបាយ ដែលមានឥទ្ធិពលទៅលើការរៀបចំផែនការសកម្មភាពនេះ។ ជំពូកទី៣ ពិភាក្សាអំពី គោលដៅ បេសកកម្ម លទ្ធផលរំពឹងទុក សូចនាករ និង សកម្មភាពអាទិភាព។ ជំពូកចុងក្រោយ ណែនាំអំពីយន្តការស្ថាប័ន សម្រាប់អនុវត្តន៍ផែនការ និងតួអង្គសំខាន់ៗដែលពាក់ព័ន្ធនៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ជាមួយនេះផងដែរ ផែនការសកម្មភាពនេះក៏មានភ្ជាប់នូវឧបសម្ព័ន្ធជាច្រើន ដែលរួមមានផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម ២០១៤-

២០១៨ សកម្មភាពជាអាទិភាពសម្រាប់ ២០១៤-២០១៨ ដោយមាននិយមន័យសម្រាប់វាក្យស័ព្ទគ្រោះមហន្តរាយ និងតារាងនៃអ្នកចូលរួមនិងកសាងផែនការសកម្មភាពនេះ។

ដោយឡែកផែនការសកម្មភាពនេះបង្ហាញអំពីផ្នែកសំខាន់ៗចំនួនប្រាំប្រទាក់ក្រឡាគ្នា ដែលឆ្លើយតបទៅនឹងក្របខ័ណ្ឌសកម្មភាពការងារហ្យោហ្គោ (១) ពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័នសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម (២) ការពង្រឹងប្រព័ន្ធប្រកាសឲ្យដឹងមុន (៣) ការបង្កើនការគ្រប់គ្រងចំណេះដឹង ការលើកកម្ពស់ការយល់ដឹង និងការអប់រំអំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (៤) ការកាត់បន្ថយកត្តាដែលជាបុព្វហេតុនៃភាពងាយរងគ្រោះដោយពង្រឹងជម្រើសបច្ចេកទេសកសិកម្ម និង (៥) ពង្រឹងសមត្ថភាពត្រៀមបង្ការសម្រាប់ការឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញប្រកបដោយប្រសិទ្ធភាពនិង សមាហរណកម្មកិច្ចអន្តរាគមន៍នៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និង ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

# ពាក្យបំព្រួញ

| | |
|---|---|
| CCA | ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| CBDRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយមានការចូលរួមពីសហគមន៍ |
| DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| EWS | ប្រព័ន្ធប្រកាសឲ្យដឹងមុន |
| FAO | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| ក.ស.ក | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| គ.ជ.គ.ម | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ធ.ទ.ឧ ខេត្ត | មន្ទីរធនធានទឹក និងឧតុនិយមខេត្ត |
| អ.ន.ក | អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

# មាតិកា

| ចំណងជើង | ទំព័រ |
|---|---|


អារម្ភកថា i
សេចក្តីថ្លែងអំណរគុណ ii
សេចក្តីសង្ខេប iii
ពាក្យបំព្រួញ v
មាតិកា vi
ជំពូកទី ១ ៖ សេចក្តីផ្តើម 1
១ ស្ថានភាពភូមិសាស្ត្រនៃខេត្តកំពង់ស្ពឺ 1
២ តម្រូវការផែនការតាមវិស័យសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម 2
៣ វិសាលភាពនៃផែនការសកម្មភាព 3
៤ គោលការណ៍ណែនាំនៃផែនការសកម្មភាព 4
៥ ដំណើរការកសាងផែនការ 5
ជំពូកទី ២ ៖ ការប្រឈមនឹងហានិភ័យគ្រោះមហន្តរាយ និងក្របខ័ណ្ឌសកម្មភាពការងារការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម 6
១ មុខសញ្ញាគ្រោះថ្នាក់គ្រោះមហន្តរាយសំខាន់ៗ ក្នុងវិស័យកសិកម្ម 6
១.១ គ្រោះរាំងស្ងួត 7
១.២ គ្រោះទឹកជំនន់ 8
១.៣ សមាសភាគចង្រៃនិងជំងឺ 8
១.៤ ខ្យល់កន្ត្រាក់ 9
១.៥ ភាពងាយរងគ្រោះ 9
២ ក្របខ័ណ្ឌគោលនយោបាយទាក់ទងនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម 10
២.១ ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣ 10
២.២ កម្មវិធីថ្នាក់ជាតិសម្រាប់សកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ 11
២.៣ យុទ្ធសាស្ត្រកសិកម្ម និងទឹក ២០១០-២០១៣ 11
២.៤ ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម ២០១៤-២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម 12
២.៥ ផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ខេត្តកំពង់ស្ពឺ ២០១២-២០១៤ 13

**ជំពូកទី ៣ ៖ ក្របខ័ណ្ឌសកម្មភាពការងារនៃផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម** 14

១ ចក្ខុវិស័យ បេសកកម្ម និងគោលបំណង 14

២ លទ្ធផលរំពឹងទុក និងសូចនាករ 14

២.១ លទ្ធផលរំពឹងទុក 14

២.២ សូចនាករ 15

៣ ក្របខ័ណ្ឌសកម្មភាការងារពជាអាទិភាព 15

៣.១ អាទិភាពទី ១ 15

៣.២ អាទិភាពទី ២ 16

៣.៣ អាទិភាពទី ៣ 17

៣.៤ អាទិភាពទី ៤ 18

៣.៥ អាទិភាពទី ៥ 19

៤ បញ្ហាអន្តរវិស័យ 20

៤.១ ការកសាងសមត្ថភាព 20

៤.២ ភាពជាដៃគូ 20

៤.៣ សមធម៌យេនឌ័រ 20

**ជំពូកទី ៤ ៖ យន្តការសម្របសម្រួល និងការអនុវត្ត** 22

១ យន្តការសម្របសម្រួលស្ថាប័ន 22

១.១ រចនាសម្ព័ន្ធស្ថាប័ននៃមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ 22

១.២ យន្តការសម្របសម្រួល 23

១.៣ ការកៀរគរមូលនិធិ និងធនធាន 24

១.៤ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ 25

២ កិច្ចសហការអន្តរស្ថាប័នក្នុងការអនុវត្តផែនការ 26

២.១ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត 26

២.២ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត 26

២.៣ អង្គការមិនមែនរដ្ឋាភិបាល 26

ឧបសម្ព័ន្ធទី១៖ ផែនការសកម្មភាពសម្រាប់ ២០១៤-២០១៨ 28

ឧបសម្ព័ន្ធទី២៖ សកម្មភាពអាទិភាពសម្រាប់ ២០១៤-២០១៨ 45

ឧបសម្ព័ន្ធទី៣៖ តារាងសង្ខេបនៃផែនការសកម្មភាព 46

ឧបសម្ព័ន្ធទី៤៖ និយមន័យ 47

ឧបសម្ព័ន្ធទី៥៖ ក្របខ័ណ្ឌសកម្មភាពការងារហ្យោហ្គោ ២០០៥-២០១៥ 50

ឧបសម្ព័ន្ធទី ៦៖ ក្រុមការងារសម្របសម្រួល និងកសាងផែនការ 52

ឯកសារយោង

# ជំពូកទី ១
# សេចក្តីផ្តើម

## ១. ស្ថានភាពភូមិសាស្ត្រនៃខេត្តកំពង់ស្ពឺ

កំពង់ស្ពឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា។ ខេត្តកំពង់ស្ពឺមានទីតាំងចម្ងាយ ៤៨ គ.ម ខាងលិចរាជធានីភ្នំពេញ ហើយមានព្រំប្រទល់ ខាងកើតជាប់នឹងខេត្តកណ្តាល តាកែវ ខាងត្បូងជាប់នឹងខេត្តតាកែវ កំពត ខាងលិចជាប់នឹងខេត្តកោះកុង និងព្រះសីហនុ និងខាងជើងជាប់នឹងខេត្តកំពង់ឆ្នាំង និងខេត្តពោធិសាត់។

រូបភាពទី ១៖ ផែនទីរដ្ឋបាលខេត្តកំពង់ស្ពឺ




ប្រភព ៖ សាលាខេត្តកំពង់ស្ពឺ

ខេត្តកំពង់ស្ពឺចែកជា ០៧ ស្រុក និង០១ ក្រុង ៨២ឃុំ ០៥ សង្កាត់ និងមាន ១,៣៤២ ភូមិក្របខ័ណ្ឌ និងភូមិអត់ក្របខ័ណ្ឌមាន ៣៨ ភូមិ។ ផ្ទៃដីសរុបក្នុងទូទាំងខេត្តមានចំនួន ៦៩៦,៦៦៣ ហិចតាហើយ ក្នុងនោះ ផ្ទៃដីស្រែ ១១៣,៦០០ ហិចតា ដីចម្ការ ចំនួន ៤៨,២៨៨ ហិចតា ដីព្រៃភ្នំ និងដីសំណង់ធារាសាស្ត្រ ៥២២,៦៧៩ ហិចតា។

ប្រជាជនសរុបមានចំនួន ១៦១,១៦២ គ្រួសារដែលមានសមាជិកចំនួន ២៥៤,៩៧៤ នាក់ ក្នុងនោះស្រី ៤១៥,៤៣៨ នាក់។ ដង់ស៊ីតេប្រជាជនមធ្យមគឺ ១១៦ នាក់ក្នុង ១ គ.ម$^{២}$។ ៦៨ ភាគរយនៃប្រជាជននៅក្នុងខេត្តកំពង់ស្ពឺគឺជាអ្នកប្រកបរបរកសិកម្ម។ ក្រៅពីនោះ ពួកគាត់ជាកម្មករក្នុងវិស័យវាយនភ័ណ្ឌ និងជាកម្មករក្រុមហ៊ុនកសិឧស្សាហកម្ម។ ប្រជាជនមួយចំនួនទៀតប្រកបមុខរបរ ធ្វើចំការ ឡើងត្នោត ធ្វើសិប្បកម្មតូចតាច និងរកចំណូលពីអនុផលព្រៃឈើ។

## ២. តម្រូវការផែនការតាមវិស័យសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម

វិស័យកសិកម្ម ជាវិស័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតដោយមុខសញ្ញាថ្នាក់ធម្មជាតិនៅក្នុងប្រទេសកម្ពុជា។ កសិករតូចតាចមានភាពងាយរងគ្រោះ ជាពិសេសដោយសារកត្តាប្រមូលផ្តុំមួយចំនួនដូចជា ការប្រឈមទៅនឹងហានិភ័យខ្ពស់ ការអនុវត្តកសិកម្មឯកវប្បកម្មអាស្រ័យទឹកភ្លៀង ទិន្នផលទាបជាទូទៅក្នុងផលិតកម្មស្រូវ និងការដាំដុះតែមួយដងក្នុងមួយរដូវ។ ខេត្តកំពង់ស្ពឺ ក៏ជួបនូវបញ្ហាទាំងអស់នេះដែរ ការប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ដែលមានកម្រិតខ្ពស់ គួបផ្សំជាមួយទិន្នផលទាបនៃផលិតកម្ម បានគំរាមកំហែងទៅដល់សុវត្ថិភាពនៃប្រព័ន្ធមុខរបររបស់គ្រួសារតូចតាចរាប់ពាន់គ្រួសារ។

នាប៉ុន្មានឆ្នាំចុងក្រោយនេះ ខេត្តកំពង់ស្ពឺប្រឈមនឹងការកើនឡើងនៃមុខសញ្ញាគ្រោះថ្នាក់គ្រោះមហន្តរាយ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ សមាសភាគចង្រៃនិងជំងឺ និងខ្យល់កន្ត្រាក់ ដែលប៉ះពាល់ទៅដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជន។ គ្រោះមហន្តរាយទាំងនេះ បង្កឲ្យមានការខូចខាត និងបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ និងកម្រិតជីវភាព។ វាក៏បានរារាំង និងបំផ្លាញដល់ការងារអភិវឌ្ឍន៍ ដែលចាំបាច់ត្រូវបង្វែរមូលនិធិសម្រាប់ការអភិវឌ្ឍទៅជួយគ្រោះមហន្តរាយវិញ ជាពិសេសគឺនៅពេលដែលគ្រោះមហន្តរាយកើតឡើង ហើយប្រជាជនមិនបានត្រៀមរៀបចំ ដែលពេលនោះពួកគាត់មិនអាចប្រឈម និងដោះស្រាយបានឡើយ។ ដោយសារកង្វះខាតផែនការ និងការវិនិយោគសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយសកម្មមុន ថវិកាជាច្រើនលានដុល្លាត្រូវបានប្រើប្រាស់សម្រាប់ការសង្គ្រោះអាយុជីវិត និងការស្តារឡើងវិញ។

ដើម្បីកាត់បន្ថយនូវការខូចខាត ការបាត់បង់ក៏ដូចជាទុក្ខលំបាករបស់កសិករដែលបណ្តាលមកពីគ្រោះមហន្តរាយនៅក្នុងវិស័យកសិកម្ម និងដើម្បីធានានិងបង្កើនផលិតផលកសិកម្ម និងជីវ-

ភាពរបស់កសិករ វាពិតជាមានតម្រូវការចាំបាច់នូវផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ ដើម្បីជួយបង្កើននូវភាពធន់ក្នុងវិស័យកសិកម្ម។ ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយលើវិស័យកសិកម្មក្នុងខេត្តកំពង់ស្ពឺ គឺជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងការកសាងសមត្ថភាពរបស់មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ដើម្បីឆ្លើយតបឲ្យកាន់តែប្រសើរឡើងចំពោះបញ្ហាកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងសមាហរណកម្មទៅក្នុងរបៀបវារៈអភិវឌ្ឍន៍ទូលំទូលាយក្នុងវិស័យ ដោយរួមបញ្ចូលការប្រែប្រួលអាកាសធាតុដែលកំពុងកើនឡើង។ ផែនការនេះផ្តល់ប្រយោជន៍ជាអតិបរមាដល់កសិករ និងសហគមន៍អាស្រ័យផលលើកសិកម្ម។

## ៣. វិសាលភាពនៃផែនការសកម្មភាព

ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងវិស័យកសិកម្ម ត្រូវបានកសាងឡើង ដោយផ្អែកលើផែនការសកម្មភាពក្នុងវិស័យកសិកម្មរបស់អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយឆ្លុះបញ្ចាំងពីផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការសកម្មភាពនេះ គឺជាឯកសារមគ្គុទេស ដែលបង្ហាញការប្តេជ្ញាចិត្តរបស់មន្ទីរកសិកម្មខេត្តកំពង់ស្ពឺដើម្បីចូលរួមចំណែកក្នុងការសម្រេចឲ្យបាននូវគោលនយោបាយជាតិនានា សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្មនៅថ្នាក់ក្រោមជាតិ។ វាបង្ហាញនូវការផ្លាស់ប្តូរជាគំរូមួយដែលបានព្រមព្រៀងនៅកម្ពុជា ពីការឆ្លើយតបសង្គ្រោះបន្ទាន់ជាលក្ខណៈបណ្តោះអាសន្ននិងចំពោះកិច្ចនាពេលកន្លងមក ឲ្យទៅជាការគ្រប់គ្រងនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយសកម្មមុននាពេលអនាគត ដោយផ្តោតសារសំខាន់ស្មើៗគ្នារវាងការងារការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំគ្រោះមហន្តរាយ។

ផែនការសកម្មភាពនេះមានរយៈពេលប្រាំឆ្នាំ ២០១៤-២០១៨។ ផែនការនេះ ផ្តោតទៅលើវិធីសាស្ត្រ និងមធ្យោបាយ ដើម្បីឆ្លើយតបទៅនឹងមុខសញ្ញាគ្រោះថ្នាក់គ្រោះមហន្តរាយធម្មជាតិមួយចំនួន ដែលប៉ះពាល់ដល់វិស័យកសិកម្ម ដូចជា រាំងស្ងួត ទឹកជំនន់ សមាសភាគចង្រៃនិងជំងឺ និងខ្យល់កន្ត្រាក់។ ផែនការនេះមានវិសាលភាពគ្របដណ្តប់តែលើវិស័យនិងអនុវិស័យមួយចំនួនដែលជាការទទួលខុសត្រូវរបស់មន្ទីរកសិកម្មខេត្តកំពង់ស្ពឺតែប៉ុណ្ណោះ។ ប៉ុន្តែផែនការនេះ ក៏អាចពង្រីកសម្រាប់អនុវិស័យផ្សេងៗទៀត ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ថ្វីបើផែនការសកម្មភាពនេះ ផ្តោតសំខាន់លើការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ប៉ុន្តែវាក៏បានផ្សាភ្ជាប់ជាមួយការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងមានបំណងស្វែងរកការផ្តុំកម្លាំង និងធនធាននានា រវាងប្រតិបត្តការដែលទាក់ទងនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ហេតុផល គឺអាស្រ័យទៅលើទស្សនៈរបស់កសិករ និងអ្នកផ្សព្វផ្សាយ ដែលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុកើតឡើងនាពេលបច្ចុប្បន្ន ទំនងជាមានឥទ្ធិពលជាញឹកញាប់និងកាន់តែធ្ងន់ធ្ងរទៅលើមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ហើយវិធានការនានាសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះហន្តរាយ និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុដែលបាននិងកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ គឺវាស្ទើរតែដូចគ្នាទាំងស្រុង។ ទស្សនៈនេះឆ្លុះបញ្ចាំងពីទស្សនវិស័យរយៈពេលខ្លី ហើយវាត្រូវបានទទួលស្គាល់នៅថ្នាក់ក្រោមជាតិ ដើម្បីផ្តល់នូវការណែនាំសម្រាប់ផែនការសកម្មភាពរយៈពេលប្រាំឆ្នាំ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាពិតជាមានសារសំខាន់ណាស់ដែលថា ផែនការសកម្មភាពនេះមិនផាត់ចោលតម្រូវការ ដើម្បីស្វែងរកប្រតិបត្តការរយៈពេលវែង ដែលអាចត្រូវការសម្រាប់ឆ្លើយតបការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ដោយប្រសិទ្ធភាពខ្ពស់នៅក្នុងវិស័យកសិកម្ម។

## ៤. គោលការណ៍ណែនាំនៃផែនការសកម្មភាព

ការកសាងផែនការសកម្មភាពនេះគឺផ្អែកទៅលើគោលការណ៍គន្លឹះមួយចំនួនដូចខាងក្រោម ដែលឆ្លើយតបទៅនឹងគោលការណ៍ណែនាំនៃគោលនយោបាយជាតិ សម្រាប់ការកាត់បន្ថយហានិ-ភ័យគ្រោះមហន្តរាយ និងផែនការសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយរបស់អគ្គនាយកដ្ឋានកសិកម្ម ៖

- បញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍កសិកម្មប្រកបដោយនិរន្តរភាព
- ធានាឲ្យមានសង្គតភាព ការបន្ត និងការសម្របសម្រួលជិតស្និទ្ធ រវាងវិធានការត្រៀមបង្ការសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការធ្វើផែនការឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ
- ប្រើប្រាស់វិធីសាស្ត្រផ្អែកលើលទ្ធផល ដើម្បីធានាពីការចូលរួមយ៉ាងពេញទំហឹងជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ រួមមានស្ថាប័នរដ្ឋាភិបាល អង្គការតាមមូលដ្ឋាន និងវិស័យឯកជន ក្នុងការរៀបចំ និងអនុវត្តផែនការ
- ទទួលស្គាល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ជាការវិនិយោគនៅក្នុងការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព
- ធានាទំនាក់ទំនងរវាងភាពធន់នៃសេដ្ឋកិច្ច និងបរិស្ថាន ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ
- ប្រើប្រាស់ចំណេះដឹង និងសមត្ថភាពដែលមាន ជាមូលដ្ឋានគ្រឹះ

- ផ្តោតលើសហគមន៍កសិករ ដែលជាអ្នកទទួលផល

## ៥. ដំណើរការរៀបចំផែនការ

ផែនការសកម្មភាពស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្មនេះ ត្រូវបានរៀបចំតាមរយៈដំណើរការពិគ្រោះយោបល់ ដែលមានបីជំហានធំៗគឺ៖

- ការប្រមូលចងក្រង និងពិនិត្យលើឯកសារមានស្រាប់៖ ការសិក្សាធ្វើឡើងដោយស៊ីជម្រៅទៅលើឯកសារដែលមាន ដូចជា គោលនយោបាយ ផែនការ សេចក្តីណែនាំ របាយការណ៍ ដែលទាក់ទងទៅនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងកសិកម្ម។ ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣ ត្រូវបានប្រើប្រាស់ជាឯកសារគោល។ គ្រោងឆ្អឹងនៃផែនការត្រូវបានរៀបចំឡើងនៅដំណាក់កាលនេះ។

- ការប្រជុំពិភាក្សាពិគ្រោះយោបល់៖ ការប្រជុំពិគ្រោះយោបល់ជាផ្លូវការ និងមិនផ្លូវការ ជាទ្វេភាគី ឬពហុភាគីត្រូវបានរៀបចំឡើង។ មន្ទីរ និងអង្គភាពជំនាញពាក់ព័ន្ធ ការិយាល័យកសិកម្មស្រុក ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ធនាគារស្រូវ និងប្រជាកសិករ ត្រូវបានជួបពិភាក្សា និងពិគ្រោះយោបល់។ បន្ថែមពីនេះទៅទៀត កិច្ចប្រជុំផ្លូវការថ្នាក់ខេត្តជាមួយអ្នកពាក់ព័ន្ធមួយចំនួននៅក្នុងខេត្តកំពង់ស្ពឺ ត្រូវបានរៀបចំ ដើម្បីប្រមូលព័ត៌មានលម្អិតបន្ថែម។ សេចក្តីព្រាងដំបូងនៃផែនការត្រូវបានរៀបចំនៅក្នុងដំណាក់កាលនេះ។

- កិច្ចប្រជុំបច្ចេកទេស ត្រួតពិនិត្យ និងកែសម្រួល៖ កិច្ចប្រជុំកម្រិតបច្ចេកទេសក្នុងក្របខ័ណ្ឌមន្ទីរកសិកម្មខេត្តកំពង់ស្ពឺត្រូវបានរៀបចំ ដើម្បីពិនិត្យខ្លឹមសារបច្ចេកទេស និង បំពេញបន្ថែមទិន្នន័យ។ បន្ទាប់មកសិក្ខាសាលាថ្នាក់ខេត្តជាមួយបណ្តាអ្នកពាក់ព័ន្ធផ្សេងៗ ក៏ត្រូវបានរៀបចំ ដើម្បីប្រមូលគំនិត យោបល់ និងត្រួតពិនិត្យ និងកែសម្រួលបន្ថែមទៀតលើខ្លឹមសារបច្ចេកទេស។ ផែនការសកម្មភាពនេះ ក៏ត្រូវបានអាន និងត្រួតពិនិត្យឡើងវិញ ដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីសម្រួល និងធានាពីសង្គតភាពនៃការប្រើប្រាស់វាក្យស័ព្ទបច្ចេកទេសក្នុងបរិបទគ្រោះមហន្តរាយ។

# ជំពូកទី ២
# ការប្រឈមនឹងហានិភ័យគ្រោះមហន្តរាយ និងក្របខ័ណ្ឌគោលនយោបាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងវិស័យកសិកម្ម

## ១. មុខសញ្ញាគ្រោះថ្នាក់គ្រោះមហន្តរាយសំខាន់ៗ ក្នុងវិស័យកសិកម្ម

កសិកម្មក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងខេត្តកំពង់ស្ពឺ បាននិងកំពុងទទួលរងនូវផលប៉ះពាល់ជាប្រចាំពីគ្រោះរាំងស្ងួតក្នុងវិស័យកសិកម្ម ទឹកជំនន់ សមាសភាគចង្រៃនិងជំងឺ និងខ្យល់កន្ត្រាក់ ។

រូបភាពទី ២ ៖ ផែនទីមុខសញ្ញាគ្រោះថ្នាក់ក្នុងវិស័យកសិកម្ម នៃខេត្តកំពង់ស្ពឺ




*ចំណាំ៖ ហានិភ័យនៃការផ្ទុះឡើងនៃសមាសភាគចង្រៃនិងជំងឺ ដែលលើសពីផ្តាសាយបក្សី គឺមិនរំលេចនៅក្នុងផែនទីនេះទេ។ ហានិភ័យកើតឡើងខ្ពស់ក្នុងតំបន់ដែលប្រកបការងារកសិកម្ម និងតំបន់ដែលមានប្រជាជនរស់នៅកុះករ។ ចំពោះតំបន់មួយចំនួន អាចមានមុខសញ្ញាគ្រោះថ្នាក់គ្រោះមហន្តរាយលើសពីមួយកើតឡើងលាយឡំគ្នា ឬជាបន្តបន្ទាប់គ្នាតែម្តង*

តារាងខាងក្រោមនេះ ប្រមូលផ្តុំទិន្នន័យ ស្តីពីផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់គ្រោះមហន្តរាយក្នុងវិស័យកសិកម្ម ក្នុងខេត្តកំពង់ស្ពឺ ចន្លោះ ឆ្នាំ ២០០៩-២០១៣ ។

| ឆ្នាំ | ផលប៉ះពាល់ (ឈើ) | | | | ការខូចខាត (ងាប់) | | | |
|---|---|---|---|---|---|---|---|---|
| | រាំងស្ងួត (ហ.ត) | សមាសភាគចម្រុះ (ហ.ត) | ទឹកជំនន់ (ហ.ត) | ជំងឺសត្វ គោ-ក្របី (ក្បាល) | រាំងស្ងួត (ហ.ត) | សមាសភាគចម្រុះ (ហ.ត) | ទឹកជំនន់ (ហ.ត) | ជំងឺសត្វ គោ-ក្របី (ក្បាល) |
| ២០១៣ | ២,២៣៩ | - | - | ២,៣៩៨ | - | - | - | ១៣៩ |
| ២០១២ | ១០,៧១៥ | - | - | ១,៥៨៤ | ៣២០ | - | - | ១៤៤ |
| ២០១១ | - | - | - | ៣,៦៩៨ | - | - | - | ១៩១ |
| ២០១០ | ១,៩២៩ | - | ១,៧៦៦ | ២,៨៤៥ | ២២៣ | - | ២៧៧ | ១២៥ |
| ២០០៩ | ១,៤៧៥ | ១,២៧០ | - | ២,៥២៤ | ៣៣២ | - | - | ១៨៩ |
| **សរុប** | **១៦,៣៥៨** | **១,២៧០** | **១,៧៦៦** | **១៣,០៤៩** | **៨៦៥** | **-** | **២៧៧** | **៧៨៨** |

ប្រភព ៖ របាយការណ៍មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ២០១៣

### ១.១. គ្រោះរាំងស្ងួត

រាំងស្ងួត សំដៅទៅលើរយៈពេលមួយដែលធាតុអាកាសក្តៅខុសពីធម្មតា ដែលអាចបង្កឲ្យមានអតុល្យភាពនៃជាតិទឹកនៅក្នុងតំបន់។ គ្រោះរាំងស្ងួតបានក្លាយជាមុខសញ្ញាគ្រោះថ្នាក់ដែលបង្កក្តីបារម្ភ និងប៉ះពាល់ដល់វិស័យកសិកម្មខ្លាំងជាងគេសម្រាប់ខេត្តកំពង់ស្ពឺ។ គ្រោះរាំងស្ងួតបានកើតឡើងក្នុងកម្រិតធ្ងន់ធ្ងរ ក្នុងឆ្នាំ១៩៨៧ ឆ្នាំ១៩៩៩ ឆ្នាំ២០០០។ គ្រោះរាំងស្ងួតទាំងបួនខាងក្រោមនេះដែលប៉ះពាល់ដល់វិស័យកសិកម្មក្នុងខេត្តកំពង់ស្ពឺ៖

ក) ការធ្លាក់ភ្លៀងយឺតនាដើមរដូវវស្សា

ខ) របាយទឹកភ្លៀងក្នុងរដូវវស្សា បរិមាណទឹកភ្លៀង និងរយៈពេលនៃការធ្លាក់ភ្លៀង នៅតាមតំបន់មិនទៀងទាត់

គ) ការឆាប់បញ្ចប់នៃរបបទឹកភ្លៀងនាចុងរដូវវស្សា (មិនជូនចុងឆ្នាំ)

ឃ) ការកើតឡើងនៃកូនរដូវប្រាំង ដែលមានរយៈពេលលើសពី ៣សប្តាហ៍ ក្នុងរដូវវស្សា ដែលអាចបំផ្លាញដំណាំនានា និងបង្អាក់ដំណើរការបង្កបង្កើនផល (ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រ ២០០៨-២០១៣)

ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ គ្រាន់តែក្នុងកំឡុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ គ្រោះរាំងស្ងួតបានបង្កផលប៉ះពាល់ដល់ផ្ទៃដីស្រែចំនួន ១៦,៣៥៨ ហិចតា និងធ្វើឲ្យខូចខាតដល់ដំណាំ ៨៦៥ ហិចតា (មន្ទីរកសិកម្មខេត្ត ២០១៣)។ ប្រជាពលរដ្ឋចំនួន ១៨,៤០០ គ្រួសារត្រូវបានប៉ាន់ស្មានថាបានទទួលរងផលប៉ះពាល់ពីគ្រោះរាំងស្ងួតស្ទើររៀងរាល់ឆ្នាំ (គណៈកម្មាធិការ

គ្រប់គ្រងគ្រោះមហន្តរាយ ខេត្តកំពង់ស្ពឺ ២០១៣)។ ឥទ្ធិពលនៃគ្រោះរាំងស្ងួតបានប៉ះពាល់ដល់អនុវិស័យផ្សេងៗទៀតដូចជាការចិញ្ចឹមសត្វ ជលផល និងសន្តិសុខស្បៀងផងដែរ។

### ១.២. គ្រោះទឹកជំនន់

មុខសញ្ញាគ្រោះថ្នាក់ទឹកជំនន់ មិនសូវបង្កផលប៉ះពាល់ធំដុំជាប្រចាំសម្រាប់វិស័យកសិកម្មក្នុងខេត្តកំពង់ស្ពឺឡើយ។ គ្រោះមហន្តរាយដោយទឹកជំនន់ខ្លាំងក្លាបានកើតឡើងក្នុងខេត្តកំពង់ស្ពឺនាឆ្នាំ ១៩៩៤ ហើយគ្រោះទឹកជំនន់ចុងក្រោយ បានកើតឡើងក្នុងឆ្នាំ ២០១០ ដោយប៉ះពាល់ដល់ស្រុកមួយចំនួន ដូចជាស្រុកសំរោងទង ក្រុងច្បារមន ស្រុកភ្នំស្រួច ស្រុកថ្ពង និងស្រុកបសេដ្ឋ។ ផ្ទៃដីកសិកម្មដែលប៉ះពាល់ដោយទឹកជំនន់មានប្រមាណ ១,៧៦៦ ហិចតា និងខូចខាតចំនួន ២៧៧ ហិចតា (មន្ទីរកសិកម្មខេត្ត ២០១៣) ។

ជាទូទៅ ជំនន់ដែលកើតក្នុងខេត្តកំពង់ស្ពឺគឺជាប្រភេទជំនន់រហ័ស ឬជំនន់ទឹកភ្លៀង ដែលបង្កឡើងពីការធ្លាក់ភ្លៀងខ្លាំងនៅតាមតំបន់ភ្នំ ហើយទឹកបានហូរតាមស្ទឹង ទៅកាន់ទន្លេសាប។ តំបន់ដែលនៅតាមដងស្ទឹងព្រែកត្នោតទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ មានដូចជា ក្រុងច្បារមន ស្រុកសំរោងទង ស្រុកឱរ៉ាល់ និងស្រុកភ្នំស្រួច។

### ១.៣. សមាសភាគចង្រៃនិងជំងឺ

ជំងឺសត្វពាហនៈជាពិសេស ជំងឺអុតក្តាម បូសខ្យល់ និងសារទឹក បានកើតឡើងស្ទើរតែគ្រប់តំបន់ទូទាំងខេត្តនាដើមនិងកំឡុងរដូវវស្សា។ តាមទិន្នន័យរបស់មន្ទីរកសិកម្មខេត្តកំពង់ស្ពឺបានបង្ហាញថា ក្នុងកំឡុង ៥ឆ្នាំចុងក្រោយនេះ (២០០៩-២០១៣) ជំងឺសត្វ បានកើតឡើងជារៀងរាល់ឆ្នាំ បង្កឲ្យសត្វគោ និងក្របីចំនួន ១៣,០៤៩ ក្បាលឈឺ ក្នុងនោះ សត្វចំនួន ៧៨៨ ក្បាលងាប់។

ជំងឺផ្តាសាយបក្សី គឺជាមុខសញ្ញាគ្រោះថ្នាក់គួរឲ្យកត់សម្គាល់សម្រាប់ផលិតកម្មបក្សី និងសុខភាពសាធារណៈ។ វាកើតដំបូងក្នុងឆ្នាំ ២០០៤ នៅភូមិទួលព្រិច ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានធ្វើឲ្យក្មេងស្រីម្នាក់ស្លាប់បាត់បង់ជីវិត។ រហូតមកទល់ពេលនេះ មានករណីផ្តាសាយបក្សីបានកើតឡើងចំនួន ៦ករណីហើយក្នុងខេត្តកំពង់ស្ពឺ។ បន្ថែមលើផលប៉ះពាល់សម្រាប់សុខភាពមនុស្ស សត្វបក្សីស្រុកមួយចំនួនធំត្រូវបានសម្លាប់ ចរាចរសត្វបក្សីត្រូវបានហាមឃាត់ និងការចិញ្ចឹមបក្សីត្រូវបានផ្អាកជាបណ្តោះអាសន្ន។

ក្រៅពីការគម្រាមកំហែងទាំងនេះ សមាសភាគចង្រៃ ដូចជាសត្វមមាចត្នោត សត្វកណ្តូប និងសត្វកណ្តុរក៏បាននិងកំពុងបំផ្លាញដល់ដំណាំស្រូវ និងដំណាំផ្សេងទៀត។ ទំហំនៃការបំផ្លាញ មិនទាន់ត្រូវបានដឹងជាក់លាក់នៅឡើយ ប៉ុន្តែមានភស្តុតាងច្បាស់លាស់ពីការបំផ្លាញនេះ ចំពោះវិស័យកសិកម្ម។ សមាសភាគចង្រៃ បានបំផ្លាញដល់ដំណាំស្រូវ ចំនួន ១,២៧០ ហិចតា ក្នុងឆ្នាំ ២០០៩

(មន្ទីរកសិកម្ម ២០១៣)។ ថ្មីៗនេះ ក៏មានវត្តមាននៃខ្យងពណ៌មាស កំពុងបំផ្លាញស្រូវពង្រោះ និងសំណាបរបស់កសិករផងដែរ ប៉ុន្តែមិនទាន់មានទិន្នន័យជាក់លាក់នៅឡើយទេ។

## ១.៤. ខ្យល់កន្ត្រាក់

ខេត្តកំពង់ស្ពឺ គឺអាចការពារបានពីខ្យល់កន្ត្រាក់ ដោយសារខេត្តនេះមានរបាំងភ្នំ ជួរភ្នំ និងព្រៃឈើជាច្រើន។ ខ្យល់ព្យុះ មិនងាយកើតឡើងទេក្នុងខេត្តនេះ។ ប៉ុន្តែគេសង្កេតឃើញមានខ្យល់ខ្លាំងក្នុងតំបន់បានកើតឡើង ដោយនាំមកជាមួយនូវទឹកភ្លៀងដែលអាចបង្កជាទឹកជំនន់រហ័ស និងបង្ករការលិចលង់ដល់ដំណាំកសិកម្មនានា។ ការបំផ្លាញដោយសារខ្យល់កន្ត្រាក់ គឺធ្វើឲ្យខូចខាតដល់ផ្ទះសម្បែងរបស់ប្រជាកសិករ និងអគារសាធារណៈមួយចំនួន។ ប៉ុន្តែ ការបំផ្លាញជាដុំកំភួនទៅលើដំណាំឈើហូបផ្លែ ឬដំណាំបន្លែផ្សេងៗគឺមិនមានទិន្នន័យនិងរបាយការណ៍ជាក់លាក់នោះទេ។

## ១.៥. ភាពងាយរងគ្រោះ

កង្វះខាតនូវចំណេះដឹងនិងការទទួលបាននូវបច្ចេកទេសកសិកម្មបន្សាំ ក្នុងបរិបទនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ គឺជាកត្តាមួយ ដែលធ្វើឲ្យសហគមន៍កសិកម្មមានភាពងាយរងគ្រោះ។ វាទាក់ទងទៅនឹងការប្រើប្រាស់ពូជមិនសមស្រប និងការប្រើប្រាស់ជីនិងថ្នាំកសិកម្មហួសកម្រិត ។

ភាពងាយរងគ្រោះផ្សេងៗទៀតរួមមានកង្វះខាត ឬការមិនដំណើការនៃប្រព័ន្ធស្រោចស្រពប្រព័ន្ធកសិកម្មនិងការចិញ្ចឹមសត្វមិនមាននិរន្តរភាព និងការប្រើប្រាស់បច្ចេកទេសកសិកម្មមិនសមស្រប។ ប្រព័ន្ធស្រោចស្រពមួយចំនួនមានសភាពទ្រុឌទ្រោម និងមិនអាចបំពេញតួនាទីបានពេញលេញក្នុងការស្តុក និងចែកចាយទឹកសម្រាប់រដូវរាំងស្ងួត ឬក៏បញ្ចៀសទឹកជំនន់។ សំខាន់ជាងនេះទៅទៀត ការផ្លាស់ប្តូរទម្លាប់យ៉ាងលឿនពីការស្ទូងស្រូវ មកធ្វើស្រូវពង្រោះ រួមផ្សំជាមួយកង្វះខាតបច្ចេកទេសសមស្រប នាំឲ្យផលិតកម្មស្រូវជួបប្រទះនូវការកើតឡើងសមាសភាគចង្រៃនិងជំងឺនានាដែលជាមូលហេតុមួយដែលធ្វើឲ្យធ្លាក់ចុះទិន្នផលស្រូវយ៉ាងគំហុកនៅក្នុងស្រុកមួយចំនួន។

ឱនភាពនៃដីត្រូវបានចាត់ទុកជាកង្វល់ផ្នែកបរិស្ថានចម្បងមួយ ដែលគំរាមកំហែងមកលើប្រព័ន្ធសន្តិសុខស្បៀង និងអាហារូបត្ថម្ភជាទូទៅផងដែរ។ ផលិតភាព ស្ថេរភាព និងនិរន្តរភាពនៃតំបន់កសិកម្មមួយផ្នែកធំនៅកម្ពុជា កំពុងរងគ្រោះដោយសារកត្តារួមគ្នាមួយចំនួននៃឱនភាពដី ពោលគឺធម្មជាតិនៃដីដែលជីជាតិតមានកំណត់ ទម្លាប់នៃការប្រើប្រាស់ដីតាមបែបប្រពៃណី និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (ពិសេសគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់) (ក.ស.ក ២០១២)។

## ២. ក្របខ័ណ្ឌគោលនយោបាយទាក់ទងនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងវិស័យកសិកម្ម

មានក្របខ័ណ្ឌគោលនយោបាយ និងកិច្ចព្រមព្រៀងជាតិមួយចំនួន ដែលកំណត់ទ្រង់ទ្រាយនៃផែនការសកម្មភាពរបស់មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្ត-រាយក្នុងវិស័យកសិកម្ម ដែលរួមមាន ៖

### ២.១. ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣

ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣ ត្រូវបានរៀបចំឡើងនៅឆ្នាំ ២០០៨ ដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពនូវក្របខ័ណ្ឌសកម្មភាពការងារយោហ្គោនៅក្នុងប្រទេសកម្ពុជា។ ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រនេះគឺមានគោលបំណងដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន ជាពិសេសជនក្រីក្រ ដែលទទួលផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ពីធម្មជាតិ។ ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រនេះ ក៏ជាមគ្គុទេសសម្រាប់បង្កើន និងអនុវត្តការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុងប្រទេសកម្ពុជា។

ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រ មានគោលបំណងសំខាន់ៗចំនួន ៦គឺ៖

- ធានាឲ្យបាននូវការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺជាអាទិភាពនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន
- ពង្រឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានសហគមន៍
- កំណត់ ប៉ាន់ប្រមាណ និងតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ និងលើកកម្ពស់ប្រព័ន្ធប្រកាសឲ្យដឹងមុន
- ប្រើប្រាស់ចំណេះដឹង ការរកឃើញថ្មី និងការអប់រំ ដើម្បីកសាងវប្បធម៌សុវត្ថិភាព និងសមត្ថភាពធន់នៅគ្រប់ថ្នាក់
- បញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងកម្មវិធីនានា របស់ក្រសួងពាក់ព័ន្ធ
- ពង្រឹងការងារត្រៀមរៀបចំសម្រាប់ការឆ្លើយតបឲ្យមានប្រសិទ្ធភាពនៅគ្រប់ថ្នាក់

រាល់សមាសធាតុនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺពិតជាមានសារសំខាន់សម្រាប់ដំណើរការកសាងផែនការសកម្មភាព និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការសកម្មភាពនេះ តាមរយៈសកម្មភាពជាក់លាក់មួយចំនួនដែលស្របតាមបរិបទនៃខេត្តកំពង់ស្ពឺ។

## ២.២. ផែនការបន្សាំថ្នាក់ជាតិទៅនឹងការប្រែប្រួលអាកាសធាតុ

កម្មវិធីថ្នាក់ជាតិសម្រាប់សកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០០៦។ ផែនការបន្សាំថ្នាក់ជាតិនេះបានផ្តល់នូវគ្រោងការណែនាំដើម្បីសម្របសម្រួល និងអនុវត្តនូវសកម្មភាពបន្សាំនានា តាមរយៈវិធីសាស្ត្រដោយមានការចូលរួម និងដើម្បីបរួមកម្លាំងជាមួយនឹងកម្មវិធីអភិវឌ្ឍន៍នានាដែលទាក់ទងនឹងបរិស្ថាន។ ផែនការបន្សាំថ្នាក់ជាតិ បានបង្ហាញនូវគម្រោងជាច្រើន ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាបន្ទាន់ និងកង្វល់នានារបស់ប្រជាជននៅថ្នាក់មូលដ្ឋានសម្រាប់ការបន្សាំទៅនឹងផលប៉ះពាល់ជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ក្នុងវិស័យ មួយចំនួន ដូចជា កសិកម្ម ធនធានទឹក តំបន់ឆ្នេរ និងសុខភាពមនុស្ស។ កម្មវិធីនេះលើកទឹកចិត្តឱ្យគ្រប់ក្រសួងនិងទីភ្នាក់ងារពាក់ព័ន្ធ អនុវត្តកិច្ចខិតខំប្រឹងប្រែងឲ្យបានជាអតិបរមា ដើម្បីធ្វើសមាហរណកម្មគម្រោងអាទិភាព ដែលបានកំណត់ក្នុងកម្មវិធីថ្នាក់ជាតិនេះ ទៅក្នុងផែនការតាមវិស័យដោយឡែកពីគ្នារបស់ពួកគេ។

## ២.៣. យុទ្ធសាស្ត្រទឹក និងកសិកម្ម ២០១០-២០១៣

យុទ្ធសាស្ត្រអន្តរវិស័យនេះត្រូវបានបង្កើតឡើងដោយស្ថាប័នជំនាញពីរ គឺក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីផ្តល់នូវក្របខ័ណ្ឌការងារយុទ្ធសាស្ត្រជារួមមួយសម្រាប់ណែនាំដល់ដំណើរការនៃការកសាងផែនការ និងគោលនយោបាយរបស់ស្ថាប័នទាំងពីរ។ យុទ្ធសាស្ត្រមានបំណងដើម្បីបង្កើនផលិតភាព និងផលិតកម្មកសិកម្ម តាមរយៈការគ្រប់គ្រង និងប្រើប្រាស់ធនធានទឹកប្រកបដោយនិរន្តរភាព និងដើម្បីបង្កើនការសម្របសម្រួលរវាងស្ថាប័នទាំងពីរដែលមានយន្តការលើការគ្រប់គ្រងទឹកប្រកបដោយភាពស្មុគស្មាញ និងឯករាជ្យពីគ្នាផងដែរ។ យុទ្ធសាស្ត្រនេះក៏បានលើកពីចំណុចដែលស្ថាប័នទាំងពីរត្រូវធ្វើការរួមគ្នាតួនាទី និងការទទួលខុសត្រូវក៏ដូចជាសមត្ថភាពនៃស្ថាប័ននីមួយៗ។ ទំនាក់ទំនងកាត់ផ្តាច់មិនបានរវាងការគ្រប់គ្រងទឹកនិងកសិកម្ម ក៏ត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ តាមរយៈវិស័យផ្សេងៗមួយចំនួនដូចជា សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ធនធានទឹកនិងការគ្រប់គ្រងដីកសិកម្ម ការគាំទ្រកសិកម្មនិងកសិឧស្សាហកម្ម និងការស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយ។ យុទ្ធសាស្ត្រនេះមានសារសំខាន់ក្នុងការបម្រើសេចក្តីត្រូវការរបស់សហគមន៍មូលដ្ឋាន ពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាងកសិកម្ម ទឹក និងការងារនៅតាមជនបទ។

## ២.៤. ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងវិស័យកសិកម្ម ២០១៤-២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម

ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមវិស័យដំបូងគេត្រូវបានរៀបចំឡើង នាឆ្នាំ២០១៣ ក្នុងគោលបំណងចូលរួមចំណែកកសាងភាពធន់របស់សហគមន៍មូលដ្ឋានទៅនឹងគ្រោះមហន្តរាយធម្មជាតិ តាមរយៈការអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្ត-រាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម។

ផែនការសកម្មភាពនេះ ត្រូវបានកសាងឲ្យស្របជាមួយផែនការសកម្មជាតិនៃយុទ្ធសាស្រ្តសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣ និងក្របខ័ណ្ឌសកម្មភាពការងារយោហ្កោ ២០០៨-២០១៥។ ផែនការសកម្មភាពនេះ មានគោលបំណងចូលរួមកសាងភាពធន់របស់កសិករនិងសហគមន៍អាស្រ័យផលនឹងកសិកម្មទៅនឹងគ្រោះមហន្តរាយធម្មជាតិ តាមរយៈការអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម។ ផែនការសកម្មភាពនេះផ្តោតទៅលើអាទិភាពចំនួន ៥គឺ៖

- អាទិភាពទី ១៖ ពង្រឹងសមត្ថភាពស្ថាប័ននិងបច្ចេកទេស និងពង្រឹងយន្តការសម្របសម្រួលសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម
- អាទិភាពទី ២៖ លើកកម្ពស់ និងជំរុញប្រព័ន្ធប្រកាសឲ្យដឹងមុន សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដោយភាពសកម្ម
- អាទិភាពទី ៣៖ ពង្រឹងការគ្រប់គ្រងចំណេះដឹងនិងគំនិតថ្មី ក្នុងការគាំទ្រដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម
- អាទិភាពទី ៤៖ កាត់បន្ថយភាពងាយរងគ្រោះដោយសារគ្រោះមហន្តរាយ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវជម្រើសបច្ចេកទេស និងការអនុវត្តវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាត ដោយមានការចូលរួមពីសហគមន៍ក្នុងវិស័យកសិកម្ម
- អាទិភាពទី ៥៖ ពង្រឹងសមត្ថភាពត្រៀមរៀបចំ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងសមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងកិច្ចអន្តរាគមន៍លើវិស័យកសិកម្ម

## ២.៥. ផែនការសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយខេត្តកំពង់ស្ពឺ ២០១២-២០១៤

ផែនការសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយខេត្តកំពង់ស្ពឺ គឺជាផែនទីបង្ហាញផ្លូវ ឬ ជាគោលការណ៍ណែនាំសម្រាប់ពង្រឹងការអនុវត្តការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងគោលបំណងដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់គ្រោះមហន្តរាយ ចំពោះជនងាយរងគ្រោះក្នុងសហគមន៍។ ផែនការសកម្មភាពនេះផ្តោតលើការអនុវត្តជាលក្ខណៈប្រព័ន្ធ ក្នុងភាពជាដៃគូរវាងអង្គភាព មន្ទីរ និងអ្នកពាក់ព័ន្ធក្នុងខេត្ត។

# ជំពូកទី ៣
# ក្របខ័ណ្ឌសកម្មភាពការងារនៃផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម

## ១. ចក្ខុវិស័យ បេសកកម្ម និងគោលដៅ

**ចក្ខុវិស័យ៖** សហគមន៍កសិកម្មមានភាពធន់នឹងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ហើយអាចដោះស្រាយទៅនឹងគ្រោះមហន្តរាយ។

**បេសកកម្ម៖** កាត់បន្ថយផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម និងជីវភាពរស់នៅរបស់កសិករ។

**គោលដៅ៖** ដើម្បីពង្រឹងសមត្ថភាព និងកសាងភាពធន់របស់កសិករ និងសហគមន៍ ទៅនឹងការគំរាមកំហែងពីគ្រោះមហន្តរាយដែលប៉ះពាល់ដល់វិស័យកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ។

## ២. លទ្ធផលរំពឹងទុក និងសូចនាករ

### ២.១ លទ្ធផលរំពឹងទុក

ផែនការសកម្មភាពនេះ នឹងសម្រេចឲ្យបាននូវលទ្ធផលដូចខាងក្រោម ៖

- វិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានដាក់បញ្ចូលទៅក្នុងរាល់ផែនការ សកម្មភាព និងកម្មវិធីតាមវិស័យ និងអនុវិស័យនានារបស់មន្ទីរកសិកម្ម
- កសិករបង្កើនការទទួលបាន និងការប្រើប្រាស់ប្រព័ន្ធប្រកាសឲ្យដឹងមុន ព័ត៌មានកសិឧតុនិយមសម្រាប់ធ្វើការសម្រេចចិត្ត តាមរយៈប្រក្រតិទិនដាំដុះប្រចាំឆ្នាំ
- ជម្រើសបច្ចេកទេសល្អៗដើម្បីបង្កើនភាពធន់ក្នុងវិស័យកសិកម្ម អាចរកបាន និងត្រូវបានអនុវត្តដោយកសិករ និងចែករំលែកយ៉ាងទូលំទូលាយ
- អ្នកធ្វើផែនការ អ្នកផ្សព្វផ្សាយថ្នាក់ក្រោមជាតិ ត្រូវបានបណ្តុះបណ្តាល ដើម្បីជំរុញយ៉ាងសកម្ម នូវបច្ចេកទេសកសិកម្មសមស្របតាមតំបន់ ដើម្បីបង្កើនភាពធន់
- កសិករត្រៀមរៀបចំ ដើម្បីដោះស្រាយមុខសញ្ញាគ្រោះថ្នាក់ និងទទួលបានជំនួយសង្គ្រោះបន្ទាន់បានទាន់ពេលវេលា ក្នុងករណីប្រកាសគ្រោះអាសន្ន

## ២.២ សូចនាករ

សូចនាករចំនួនបីត្រូវបានកំណត់សម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ បន្ទាប់ពីរយៈពេលបីឆ្នាំនៃការអនុវត្តផែនការ៖

- កម្រិតនៃការពេញចិត្តរបស់កសិករចំពោះសេវាកម្មផ្សព្វផ្សាយកសិកម្ម នៅគ្រប់កម្រិត
- ចំនួនកសិករដែលអនុវត្តជម្រើសល្អ និងបច្ចេកទេសកសិកម្មភាពធន់
- ភាគរយនៃកសិករដែលប៉ះពាល់ដោយអសន្តិសុខស្បៀង បន្ទាប់ពីគ្រោះមហន្តរាយបានកើតឡើង

សូចនាករជាក់លាក់ជាច្រើនទៀតសម្រាប់សកម្មភាពនីមួយៗ នឹងត្រូវបានរៀបចំនៅពេលក្រោយទៀត ដែលជាផ្នែកមួយនៃផែនការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដែលត្រូវបានបង្កើតរួមគ្នាជាមួយការរៀបចំសម្រាប់ការអនុវត្តផែនការសកម្មភាពនេះ។

# ៣. ក្របខ័ណ្ឌសកម្មភាពការងារ ជាអាទិភាព

ផែនការសកម្មភាព សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ លើវិស័យកសិកម្មក្នុងខេត្តកំពង់ស្ពឺ ត្រូវបានកសាងដោយស្របតាមផែនការសកម្មភាពជាតិនៃយុទ្ធសាស្រ្ត ២០០៨-២០១៣ របស់ គ.ជ.គ.ម. និងផែនការសកម្មភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងវិស័យកសិកម្មរបស់ អ.ន.ក ។ ផែនការសកម្មភាពនេះ មានអាទិភាពសំខាន់ៗចំនួន៥ ៖

## ៣.១. អាទិភាពទី ១៖ ពង្រឹងសមត្ថភាពស្ថាប័ននិងបច្ចេកទេស និងបង្កើនយន្តការសម្របសម្រួលសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម

**គោលបំណង៖** ពង្រឹងយន្តការនិងដំណើរការស្ថាប័នឲ្យមានប្រសិទ្ធភាពនៅក្នុងមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ដើម្បីដោះស្រាយការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ពាក់ព័ន្ធនឹងផលិតកម្មដំណាំនិងផលិតកម្មសត្វ និងសមាហរណកម្មសកម្មភាពទាំងនេះទៅក្នុងអាទិភាពនៃការអភិវឌ្ឍរបស់មន្ទីរកសិកម្ម ដោយពង្រឹងការសម្របសម្រួលជាមួយមន្ទីរជុំវិញខេត្ត និងអ្នកពាក់ព័ន្ធនានា។

**ចំណុចខ្វះខាតត្រូវដោះស្រាយ៖** កង្វះខាតចំណេះដឹង និងសមត្ថភាពរបស់ស្ថាប័នធ្វើការផ្នែកកសិកម្មក្នុងការរៀបចំកម្មវិធី និងអនុវត្តន៍គម្រោងនិងសកម្មភាព ដើម្បីដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ។

កង្វះខាតធនធាននៅក្នុងមន្ទីរកសិកម្ម សម្រាប់អនុវត្តការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការសម្របសម្រួល និងសហប្រតិបត្តការអន្តរស្ថាប័ន។

**យុទ្ធសាស្ត្រ៖** ពង្រឹងសមត្ថភាពស្ថាប័ននិងបច្ចេកទេស និងសមាហរណកម្មការកាត់បន្ថយហានិ-ភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការ និងកម្មវិធីនានាក្នុង វិស័យកសិកម្ម។

៣.១.១ ពង្រឹងយន្តការស្ថាប័នសម្រាប់ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងស្ថាប័នជំនាញ និងអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្ត សម្រាប់ការអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ

៣.១.២ ពង្រឹងសមត្ថភាពស្ថាប័នរបស់មន្ទីរកសិកម្ម និងការិយាល័យកសិកម្មស្រុក សម្រាប់ការអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព

## ៣.២. អាទិភាពទី ២៖ ជំរុញ និងពង្រឹងប្រព័ន្ធប្រកាសឲ្យដឹងមុនសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុដោយភាពសកម្ម

**គោលបំណង៖** បង្កើនការផ្សព្វផ្សាយព័ត៌មានអាកាសធាតុ និងព័ត៌មានប្រកាសឲ្យដឹងមុន (ដែលទទួលបានពី អ.ន.ក) រួមមាន ព័ត៌មានអាកាសធាតុនិងធាតុអាកាស ក្នុងកម្រិតពេលវេលាផ្សេងៗគ្នា ព័ត៌មានតម្លៃទីផ្សារនៃកសិផល និងព័ត៌មានព្យាករណ៍ពីការផ្ទុះឡើងនៃសមាសភាគចង្រៃសម្រាប់ដំណាំ និងជំងឺសត្វ ទៅដល់កសិករ និងសហគមន៍អាស្រ័យផលលើកសិកម្ម។

**ចំណុចខ្វះខាតត្រូវដោះស្រាយ៖** ព័ត៌មានប្រកាសឲ្យដឹងមុននិងព័ត៌មានអាកាសធាតុមិនសមស្របសម្រាប់ការប្រើប្រាស់ជាក់លាក់ក្នុងវិស័យកសិកម្ម កង្វះខាតការទទួលបានព័ត៌មានទាន់ពេលវេលា និងសុក្រិតភាពនៃព័ត៌មានមានតិចតួច កម្សោយនៃបណ្តាញទំនាក់ទំនងសម្រាប់ការផ្តល់ព័ត៌មានអាកាសធាតុនិងធាតុអាកាស និងព័ត៌មានប្រកាសឲ្យដឹងមុនទៅដល់កសិករ។

**យុទ្ធសាស្ត្រ៖** (១) បង្កើនការសម្របសម្រួល និងសហការរវាងមន្ទីរពាក់ព័ន្ធ និងអ្នកផ្តល់សេវាកម្មដើម្បីផ្តល់ទិន្នន័យនិងព័ត៌មានប្រកាសឲ្យដឹងមុនជាប្រចាំ និងឲ្យទាន់ពេលវេលាសម្រាប់វិស័យកសិកម្ម និងកែសម្រួលព័ត៌មានទាំងនោះឲ្យសមស្របតាមតម្រូវការរបស់កសិករ (២)ជំរុញការបង្កើតសេវាកម្មផ្តល់ព័ត៌មានអាកាសធាតុជាក់លាក់ និងប្រព័ន្ធប្រកាសឲ្យដឹងមុនសម្រាប់វិស័យកសិកម្ម និង (៣) ពង្រឹងបណ្តាញទំនាក់ទំនងនិងលំហូរនៃព័ត៌មាន ដើម្បីជំរុញការផ្សព្វផ្សាយព្រឹត្តបត្រព័ត៌មាន និងព័ត៌មានប្រកាសឲ្យដឹងមុនជាក់លាក់ទៅដល់សហគមន៍មូលដ្ឋាន។

៣.២.១ ជំរុញ និងគាំទ្រការផ្លាស់ប្តូរទិន្នន័យសម្រាប់សេវាកម្មអាកាសធាតុ និងព័ត៌មានប្រកាសឲ្យដឹងមុនក្នុងវិស័យកសិកម្ម ជាមួយមន្ទីរ និងអ្នកពាក់ព័ន្ធនានា

៣.២.២ ជំរុញការផលិតព័ត៌មានអាកាសធាតុជាក់លាក់ និងព័ត៌មានប្រកាសឲ្យដឹងមុនដែលកែសម្រួលទៅតាមតម្រូវការក្នុងវិស័យកសិកម្ម

៣.២.៣ ពង្រឹងបណ្តាញទំនាក់ទំនង សម្រាប់ការផ្សព្វផ្សាយព័ត៌មានទៅដល់កសិករ និងសហគមន៍អាស្រ័យផលលើកសិកម្ម

## ៣.៣. អាទិភាពទី ៣៖ ពង្រឹងការគ្រប់គ្រងចំណេះដឹង និងគំនិតផ្តួចផ្តើមថ្មីក្នុងការគាំទ្រដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម

**គោលបំណង៖** ពង្រឹងចំណេះដឹងជាមូលដ្ឋាន និងទំនាក់ទំនងសម្រាប់ការកសាងផែនការ និងការសម្រេចចិត្តផ្អែកលើសក្ខីកម្ម និងការផ្សព្វផ្សាយព័ត៌មានសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម។

**ចំណុចខ្វះខាតត្រូវដោះស្រាយ៖** ភាពសម្បូរបែបនៃចំណេះដឹងបច្ចេកទេសតាមមូលដ្ឋានដែលជំរុញភាពធន់នៃជម្រើសមុខរបររបស់កសិករមិនទាន់ត្រូវបានវិភាគ ឬកត់ត្រានៅឡើយ។ ចំណេះធ្វើស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្មមិនទាន់ត្រូវបានបញ្ជាក់ពីភាពត្រឹមត្រូវ ឬចែករំលែកទូលំទូលាយនៅឡើយ។ មិនទាន់មានយុទ្ធសាស្ត្រសម្រាប់ការពង្រីកបទពិសោធន៍ និងការអនុវត្តល្អៗដែលទទួលបានជោគជ័យ ឬសម្រាប់បន្សាំទៅតាមលក្ខខណ្ឌតំបន់ និងតម្រូវការជាក់លាក់។ មិនទាន់មានវិធីសាស្ត្រតាមមូលដ្ឋានដើម្បីចងក្រង និងផ្សព្វផ្សាយគំនិតផ្តួចផ្តើមថ្មីសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ខណៈពេលដែលវានៅលាយឡំជាមួយចំណេះដឹងដែលមានស្រាប់តាមមូលដ្ឋាន។ លើសពីនេះទៀត ការយល់ដឹងនៅមានកម្រិតនៅឡើយក្នុងចំណោមសហគមន៍កសិកម្មអំពីផលប្រយោជន៍ និងតម្លៃបន្ថែម ដែលពួកគាត់អាចទទួលបានពីការអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយសកម្ម។

**យុទ្ធសាស្ត្រ៖** បង្កើនការទទួលបាននូវទិន្នន័យ ការគ្រប់គ្រងចំណេះដឹងនិងការផ្សព្វផ្សាយព័ត៌មានតាមរយៈការពង្រឹងបណ្តាញទំនាក់ទំនង និងយុទ្ធសាស្ត្របង្កើនការយល់ដឹងពីជម្រើស និងតម្លៃបន្ថែមនៃវិធានការនានានៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

៣.៣.១ ពង្រឹង និងឬភ្ជាប់ទិន្នន័យទាក់ទងនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីរៀបចំផែនការ និងការសម្រេចចិត្តឲ្យកាន់តែប្រសើរឡើង

៣.៣.២ បង្កើនមូលដ្ឋាន ចំណេះដឹង និងជំរុញគំនិតផ្តួចផ្តើមថ្មីសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម ដោយរួមបញ្ចូលការចងក្រងនិងផ្សព្វផ្សាយបច្ចេកទេសល្អៗ

៣.៣.៣ បង្កើនការយល់ដឹង និងទំនាក់ទំនងសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម

## ៣.៤. អាទិភាពទី ៤៖កាត់បន្ថយភាពងាយរងគ្រោះតាមរយៈការបង្កើនជម្រើសបច្ចេកទេសក្នុងវិស័យកសិកម្ម និងការលើកកំពស់ដំណើរការនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុដោយមានការចូលរួមពីសហគមន៍

**គោលបំណង៖** កសាងភាពធន់ទៅនឹងការប្រឈមនៃមុខសញ្ញាគ្រោះថ្នាក់នៅកម្រិតមូលដ្ឋាន និងកាត់បន្ថយកត្តាដែលបង្កហានិភ័យ ដែលបង្កើនភាពងាយរងគ្រោះសម្រាប់សហគមន៍កសិកម្មនិងគ្រួសារកសិករ។

**ចំណុចខ្វះខាតត្រូវដោះស្រាយ៖** ការប្រើប្រាស់មិនទាន់បានគ្រប់គ្រាន់នូវបច្ចេកទេសល្អៗ ដែលអាចកាត់បន្ថយភាពងាយរងគ្រោះនៃប្រព័ន្ធកសិកម្ម និងផលិតកម្មកសិកម្មជាលក្ខណៈគ្រួសារ។ តម្រូវការក្នុងការផ្លាស់ប្តូរបច្ចេកទេសដែលមិនមាននិរន្តរភាព ដែលកាត់បន្ថយភាពធន់ក្នុងរយៈពេលខ្លី និងរយៈពេលវែង ដូចជាកសិកម្មឯកវប្បកម្ម កង្វះខាតការគ្រប់គ្រងដីជាតិដី ការប្រើប្រាស់ជី និងថ្នាំកសិកម្មហួសកម្រិត កង្វះខាតការគ្រប់គ្រងទឹកនិងការថែរក្សាទឹក និងផលិតកម្មចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដោយព្រលែងជាដើម។

**យុទ្ធសាស្ត្រ៖** បង្កើនភាពធន់នៃមុខរបរទៅនឹងគ្រោះមហន្តរាយ បង្កើនសមត្ថភាពដល់បុគ្គលិកបច្ចេកទេសនិងសហគមន៍ បង្កើនការទទួលបានរបស់កសិករនូវបច្ចេកទេសល្អៗជាច្រើនដែលកាត់បន្ថយការប្រឈមហានិភ័យនៃមុខសញ្ញាគ្រោះថ្នាក់ បន្ធូរបន្ថយការខូចខាតនិងបាត់បង់ និងបង្កើនឱកាសសម្រាប់មុខរបរបន្ថែម និងយន្តការផ្ទេរហានិភ័យ និងជម្រុញការពង្រីកបន្ថែមបច្ចេកទេសល្អៗសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។

៣.៤.១ ជំរុញប្រព័ន្ធកសិកម្មចម្រុះ និងពិពិធកម្មដំណាំ ដើម្បីកសាងភាពធន់របស់សហគមន៍កសិកម្មទៅនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយ

៣.៤.២ បង្កើនផលិតកម្មសត្វនៅគ្រប់កម្រិត

៣.៤.៣ ជំរុញការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព និងការថែរក្សាទឹក នៅលើវាលស្រែ

៣.៤.៤ ជំរុញយន្តការផ្ទេរហានិភ័យ

៣.៤.៥ កាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីការប្រើប្រាស់ជីនិងថ្នាំកសិកម្ម កម្រិតខេត្ត និងមូលដ្ឋាន

## ៣.៥. អាទិភាពទី ៥៖ ពង្រឹងសមត្ថភាពត្រៀមរៀបចំ និងឆ្លើយតបឲ្យមានប្រសិទ្ធភាព និងសមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការឆ្លើយតបសង្គ្រោះបន្ទាន់ក្នុងវិស័យកសិកម្ម

**គោលបំណង៖** បង្កើនសមត្ថភាពរបស់មន្ទីរជុំវិញខេត្ត អាជ្ញាធរមូលដ្ឋាន និងសហគមន៍កសិកម្មស្ដីពីការត្រៀមរៀបចំឲ្យប្រសើរសម្រាប់ការឆ្លើយតបសង្គ្រោះបន្ទាន់ ធានាការធ្វើការប៉ាន់ប្រមាណ និងការផ្ដល់នូវជំនួយសង្គ្រោះបន្ទាន់ទាន់ពេលវេលានៅក្នុងវិស័យកសិកម្ម និងក្នុងករណីដែលគ្រោះអាសន្នត្រូវបានប្រកាស។ ផ្ដល់នូវការណែនាំជាយុទ្ធសាស្ត្រសម្រាប់ការស្ដារឡើងវិញ និងការកសាងឡើងវិញ ដោយធានាថាទស្សនទាននៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានដាក់បញ្ចូលទៅក្នុងការអនុវត្តការងារទាំងឡាយដែលពាក់ព័ន្ធ។

**ចំណុចខ្វះខាតត្រូវដោះស្រាយ៖** ធនធាន (មនុស្សនិងថវិកា) នៅមានកម្រិតសម្រាប់មន្ទីរកសិកម្មសម្រាប់ការឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្ដារឡើងវិញឲ្យបានគ្រប់គ្រាន់និងមានប្រសិទ្ធភាព។ ការឆ្លើយតបសង្គ្រោះបន្ទាន់នៅតែធ្វើជាលក្ខណៈបណ្ដោះអាសន្ន និងផ្ដោតលើតម្រូវការបន្ទាន់ និងការជួសជុលទ្រព្យសម្បត្តិតែប៉ុណ្ណោះ។

**យុទ្ធសាស្ត្រ៖** ជំរុញការកសាងផែនការត្រៀមបម្រុងជាលក្ខណៈប្រព័ន្ធនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក និងគាំទ្រដល់ដំណើរការផ្លាស់ប្ដូរជាគំរូ ពីការគ្រប់គ្រងគ្រោះមហន្តរាយបែបអកម្មទៅជាវិធីសាស្ត្ររួមបញ្ចូលគ្នា ដែលផ្សារភ្ជាប់ជាលក្ខណៈប្រព័ន្ធនូវការត្រៀមរៀបចំគ្រោះអាសន្ន ការឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្ដារឡើងវិញ ជាមួយនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងរយៈពេលវែង។

៣.៥.១ ពង្រឹងសមត្ថភាពធនធានរបស់មន្ទីរកសិកម្មខេត្ត ក្នុងការរៀបចំផែនការត្រៀមបម្រុងជាប្រចាំ និងសមាហរណកម្មទៅក្នុងផែនការ និងសកម្មភាពដែលកំពុងដំណើរការ

៣.៥.២ បង្កើនប្រសិទ្ធភាពនៃសកម្មភាពឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញក្រោយគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម និងបញ្ចូលអន្តរាគមន៍ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងវិធានការស្តារឡើងវិញ និងកសាងឡើងវិញ

# ៤. បញ្ហាអន្តរវិស័យ

ផែនការសកម្មភាពស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ផ្តោតទៅលើការងារអន្តរវិស័យចំនួន ៣ ដែលជាផ្នែកនៃសកម្មភាពអាទិភាពខាងលើ។

## ៤.១. ការកសាងសមត្ថភាព

កសាងសមត្ថភាពបច្ចេកទេសនិងស្ថាប័ន គឺមានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តផែនការសកម្មភាពនេះឲ្យមានប្រសិទ្ធភាព។ ការអភិវឌ្ឍសមត្ថភាព ត្រូវបានអនុវត្តជាពិសេសនៅក្នុងអាទិភាពទី ១ ប៉ុន្តែវាក៏នឹងត្រូវបានអនុវត្តជាទូទៅសម្រាប់អាទិភាពផ្សេងៗទៀតដែរ ទៅតាមតម្រូវការជាក់ស្តែង។ ចំណុចសំខាន់នៃការកសាងសមត្ថភាពរួមបញ្ចូលទាំងការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការផ្លាស់ប្តូរបច្ចេកទេស ឧបករណ៍ និងវិធីសាស្រ្តនៃការធ្វើការប៉ាន់ប្រមាណ សេវាកម្មកសិកម្ម ការតស៊ូមតិផ្នែកនយោបាយ និងការបង្កើន និងបញ្ជ្រាបការយល់ដឹង។

## ៤.២. ភាពជាដៃគូ

ភាពជាដៃគូយុទ្ធសាស្រ្តជំរុញនូវវិធីសាស្រ្តអន្តរជំនាញ ក្នុងការអនុវត្តផែនការសកម្មភាពនេះ។ ផែនការសកម្មភាពនេះប្រមើលមើលពីភាពជាដៃគូនៅគ្រប់កម្រិតទាំងអស់ ពីថ្នាក់ជាតិ រហូតដល់ថ្នាក់មូលដ្ឋាន ជាពិសេសជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត មន្ទីរធនធានទឹកនិងឧតុនិយមខេត្ត និងបណ្តាមន្ទីរផ្សេងៗ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល និងសមាគមតាមមូលដ្ឋានផងដែរ។ ផែនការសកម្មភាពនេះក៏នឹងស្វែងរកការកសាងភាពជាដៃគូជាមួយអាជ្ញាធរថ្នាក់ស្រុក និងឃុំនៅក្នុងតំបន់ដែលប្រឈមនឹងគ្រោះមហន្តរាយផងដែរ។

## ៤.៣. សមធម៌យេនឌ័រ

បញ្ហាយេនឌ័រគឺជាបញ្ហាសំខាន់នៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងនៅក្នុងវិស័យកសិកម្ម។ តួនាទី និងទំនាក់ទំនងយេនឌ័របានជះឥទ្ធិពលដល់សន្តិសុខស្បៀងនិងសុខុមាល-ភាពរបស់គ្រួសារ និងសូចនាករសំខាន់ៗនៃការអភិវឌ្ឍកសិកម្ម។ អតុល្យភាពយេនឌ័រ ក្នុងការទទួល

បាននិងគ្រប់គ្រងលើធនធាន គឺជាឧបសគ្គដែលបានជះឥទ្ធិពលដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងសម្រេចចិត្ត គឺមានចំនួនតិចតួចបំផុតនៅក្នុងវិស័យនេះ។ ការបញ្ជ្រាបអាទិភាពយេនឌ័រទៅក្នុងរាល់សកម្មភាពនៃផែនការសកម្មភាព គឺមានសារសំខាន់ ដើម្បីបង្កើនភាពធន់រយៈពេលវែង។

# ជំពូកទី ៤
# យន្តការសម្របសម្រួល និងការអនុវត្ត

## ១. យន្តការសម្របសម្រួលស្ថាប័ន

យន្តការសម្របសម្រួលស្ថាប័ន សម្រាប់ការអនុវត្តផែនការសកម្មភាពនេះ រួមមាន យន្តការសម្របសម្រួល រចនាសម្ព័ន្ធស្ថាប័ន ការកៀរគរធនធាន ក៏ដូចជាការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដែលសុទ្ធតែមានសារសំខាន់ ដើម្បីសម្រេចបាននូវគោលបំណងនៃផែនការសកម្មភាព ក៏ដូចជាផែនការសកម្មភាពជាអាទិភាពមួយចំនួន។

### ១.១. រចនាសម្ព័ន្ធស្ថាប័ននៃមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ

មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ គឺជាស្ថាប័នរាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិមួយ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ មានអាណត្តិការងារសម្រាប់ផលិតកម្មដំណាំ ការផ្សព្វផ្សាយកសិកម្ម ការគ្រប់គ្រងនិងកែលំអធនធានដីកសិកម្ម និងផលិតកម្មនិងបសុព្យាបាល។ មន្ទីរកសិកម្មខេត្ត ស្ថិតក្រោមការគ្រប់គ្រងប្រចាំថ្ងៃរបស់ប្រធានមន្ទីរមួយរូប និងមានអនុប្រធានចំនួន ៣រូប។ នៅក្នុងមន្ទីរកសិកម្ម មានការិយាល័យ (ការិ.) ចំនួន ៨ ដែលក្នុងនោះ រួមមាន ការិ. រដ្ឋបាលនិងបុគ្គលិក ការិ. ផែនការនិងគណនេយ្យ ការិ. ក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ការិ. ផលិតកម្មនិងបសុព្យាបាល ការិ. ផ្សព្វផ្សាយកសិកម្ម ការិ. គ្រឿងយន្តកសិកម្ម ការិ.និតិកម្មកសិកម្ម និងការិ. កសិឧស្សាហកម្ម។ មន្ទីរកសិកម្មខេត្តកំពង់ស្ពឺក៏គ្រប់គ្រងការិយាល័យកសិកម្មស្រុក/ក្រុងចំនួន ៨ ដែរ រួមមាន ការិ. កសិកម្មក្រុងច្បារមន ការិ. កសិកម្មស្រុកគងពិសី ការិ. កសិកម្មស្រុកបសេដ្ឋ ការិ. កសិកម្មស្រុកឧដុង្គ ការិ. កសិកម្មស្រុកសំរោងទង ការិ. កសិកម្មស្រុកថ្ពង ការិ. កសិកម្មស្រុកភ្នំស្រួច និងការិ. កសិកម្មស្រុកឱរ៉ាល់។

នៅពេលបច្ចុប្បន្ន មន្ទីរកសិកម្មខេត្តកំពង់ស្ពឺពុំទាន់មានការិយាល័យ ឬក្រុមការងារជាក់លាក់សម្រាប់ការសម្របសម្រួលការងារការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុនៅឡើយទេ។

រូបភាពទី៣ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ




## ១.២. យន្តការសម្របសម្រួល

ការណែនាំអំពីអាទិភាព និងវិធីសាស្ត្រថ្មីៗសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងមន្ទីរកសិកម្ម ដែលទាក់ទងជាមួយអ្នកពាក់ព័ន្ធ និងមន្ទីរផ្សេងៗ តម្រូវឲ្យមានការព្រមព្រៀងគ្នា និងជំរុញការងារគ្រប់គ្រង ព្រមទាំងរចនាសម្ព័ន្ធអនុវត្តន៍។ ដូច្នេះ រចនាសម្ព័ន្ធសម្រាប់ការគ្រប់គ្រងផែនការសកម្មភាពស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ត្រូវបានពិចារណា មានដូចខាងក្រោម៖

គណៈកម្មាធិការអចិន្ត្រៃយ៍ មានតួនាទីផ្តល់ការចង្អុលទិស និងការត្រួតពិនិត្យជារួម។ គណៈកម្មាធិការនេះមានសមាសភាពរួមមានប្រធានមន្ទីរ និងអនុប្រធានមន្ទីរ។ គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវមានគណនេយ្យភាពចំពោះមន្ទីរកសិកម្ម លើការអនុវត្ត និងការត្រួតពិនិត្យវឌ្ឍនភាពនៃផែនការសកម្មភាពនេះ។

គណៈកម្មាធិការអចិន្ត្រៃយ៍ ទទួលបានការគាំទ្រពីក្រុមការងារបច្ចេកទេស ដែលបញ្ជាដោយផ្ទាល់ពីប្រធានមន្ទីរ។ សមាសភាពក្រុមការងារបច្ចេកទេសមានការិយាល័យជំនាញ និងការិយាល័យកសិកម្មស្រុក។ ក្រុមការងារបច្ចេកទេសនេះ នឹងណែនាំ និងអនុវត្តកត្វកិច្ចចំនួន បីសំខាន់ៗគឺ ៖

- កសាងសមត្ថភាពនិងផែនការៈ កសាងសមត្ថភាពដល់មន្ទីរកសិកម្មខេត្ត ការិយាល័យកសិកម្មស្រុក ក៏ដូចជាឃុំគោលដៅមួយចំនួន និងធានាចំពោះការធ្វើសមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងការធ្វើផែនការកសិកម្មនៅគ្រប់កម្រិត។
- ការប៉ាន់ប្រមាណនិងឆ្លើយតបសង្គ្រោះបន្ទាន់ៈ ធ្វើការប៉ាន់ប្រមាណតម្រូវការ ការវាយតម្លៃផលប៉ះពាល់នៃគ្រោះមហន្តរាយ ការប្រមូលទិន្នន័យ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ដែលពាក់ព័ន្ធនឹងការបាត់បង់ និងការខូចខាតដោយគ្រោះមហន្តរាយនៅក្នុងវិស័យកសិកម្ម។ ការងារនេះមានលក្ខណៈបន្ទាន់និងចំពោះកិច្ច ហើយក្រុមការងារអាចចាប់ផ្តើមដំណើរការសកម្មភាពក្នុងរយៈពេល ២៤ម៉ោង ក្រោយពេលមានគ្រោះអាសន្នកើតឡើង ដើម្បីឆ្លើយតបសង្គ្រោះបន្ទាន់។ ប្រធានការិយាល័យកសិកម្មស្រុកនីមួយៗ គឺជាសមាជិកនៃក្រុមការងារនេះ។
- កសិកម្មភាពធន់ៈ ប្រចាប់បញ្ចូលគ្នានូវចំណេះដឹងបច្ចេកទេសកសិកម្ម ជាមួយគោលគំនិតនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងធ្វើការស្រាវជ្រាវនិងអភិវឌ្ឍន៍ជម្រើសបច្ចេកទេសល្អសម្រាប់កសិកម្មភាពធន់។

ក្រុមការងារបច្ចេកទេស និងក្រុមការងារតូចៗទៀត អាចត្រូវបានបង្កើតឡើងសម្រាប់អនុវត្តន៍ការងារខាងលើ។

គណៈកម្មាធិការអចិន្ត្រៃយ៍ និង ក្រុមការងារបច្ចេកទេស នឹងមានការគាំទ្រពីលេខាធិការដ្ឋានដែលដើរតួនាទី ជាពិសេស ក្នុងការត្រួតពិនិត្យតាមដាននិងវាយតម្លៃ និងធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពនេះ។ ការិយាល័យរដ្ឋបាលនិងបុគ្គលិក ត្រូវបានស្នើឲ្យធ្វើជាលេខាធិការដ្ឋានសម្រាប់រាល់ការសម្របសម្រួល និងការអនុវត្តផែនការសកម្មភាពនេះ។

## ១.៣. ការកៀរគរមូលនិធិ និងធនធាន

មូលនិធិសម្រាប់អនុវត្តផែនការសកម្មភាព នឹងត្រូវវិភាជន៍ពីថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់មូលដ្ឋាន។ ក្រៅពីនេះ មានប្រភពមូលនិធិចំនួនបី ទៀតគឺ មូលនិធិខាងក្នុង មូលនិធិខាងក្រៅ និងមូលនិធិច្នៃប្រឌិត។

ប្រភពមូលនិធិខាងក្នុងរួមមាន ប្រភពហិរញ្ញវត្ថុដែលកៀរគរពីក្នុងប្រទេសកម្ពុជា ដែលក្នុងនោះរួមមានដូចជា ថវិកាសាធារណៈបច្ចុប្បន្ន មូលនិធិពីវិស័យឯកជន មូលនិធិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រភពមូលនិធិផ្សេងៗទៀតនៅក្នុងស្រុក។

ប្រភពមូលនិធិខាងក្រៅ រួមមានជំនួយឥតសំណង ជំនួយទ្វេភាគី ពហុភាគីពីអង្គការមិនមែនរដ្ឋាភិបាល និងមូលនិធិសប្បុរសធម៌នានា ។ល។ ប្រភពមូលនិធិខាងក្រៅមិនមានភាពជាក់

លាក់ឡើយ ប៉ុន្តែប្រភពមូលនិធិនេះ មានសារៈសំខាន់ ហើយសកម្មភាពជាច្រើនត្រូវបានអនុវត្តតាមរយៈមូលនិធិនេះ ដោយដៃគូអភិវឌ្ឍន៍ និងបណ្តាអង្គការមិនមែនរដ្ឋាភិបាល។

ប្រភពមូលនិធិច្នៃប្រឌិតដែលកំពុងស្វែងរក តំណាងឲ្យរបៀបផ្តល់ហិរញ្ញប្បទានថ្មីមិនមែនបែបប្រពៃណី។ ថ្មីៗនេះ យន្តការផ្តល់ហិរញ្ញប្បទានច្នៃប្រឌិត ត្រូវបានគេមើលឃើញកាន់តែច្រើនថាជាប្រភពមូលនិធិដែលមានស្ថេរភាព និងមាននិរន្តរភាព ដែលមិនរងផលប៉ះពាល់ពីការផ្លាស់ប្តូរចលនានយោបាយ ឬ គោលនយោបាយ និងគំរូរបស់ម្ចាស់ជំនួយ។ មូលនិធិទាំងអស់នេះរួមមានមូលនិធិសកលសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៃជំនួយមនុស្សធម៌និងកិច្ចគាំពារជនស៊ីវិលនៃសហគមន៍អឺរ៉ុប មូលនិធិសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច មូលនិធិអាកាសធាតុបៃតង ឬ មូលនិធិសម្រាប់ការបន្សាំដែលស្ថិតក្រោមអនុសញ្ញាក្របខ័ណ្ឌសកម្មភាពការងារការប្រែប្រួលអាកាសធាតុនៃសហប្រជាជាតិ។ កាលានុវត្តភាពដទៃទៀតរួមមានការទទួលបានមូលនិធិតាមរយៈយន្តការបង់ប្រាក់សម្រាប់សេវាកម្មបរិស្ថាន ការកាត់បន្ថយការភាយឧស្ម័នផ្ទះកញ្ចក់ពីការបំផ្លាញនិងការបាត់បង់ព្រៃឈើ និងយន្តការអភិវឌ្ឍន៍ស្អាតជាដើម។

## ១.៤. ការត្រួតពិនិត្យ និងវាយតម្លៃ

គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវបង្កើតផែនការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីជារួម សម្រាប់ផែនការសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ផែនការនេះ ត្រូវផ្អែកលើរបាយការណ៍ស្តីពីលទ្ធផល និងសូចនាករនៅក្នុងផ្នែកមុនៗ។ សូចនាករសមស្រប និងកាន់តែជាក់លាក់ នឹងត្រូវបានរៀបចំនៅក្នុងផែនការត្រួតពិនិត្យនិងវាយតម្លៃ ដែលនឹងត្រូវរៀបចំឡើងជាផ្នែកមួយនៃការចាប់ផ្តើមសកម្មភាពមុនពេលអនុវត្តន៍ផែនការសកម្មភាព។

ផែនការត្រួតពិនិត្យនិងវាយតម្លៃ ត្រូវផ្តល់ការណែនាំអំពីរបៀបតាមដានវឌ្ឍនភាពនៃផែនការសកម្មភាព និងដាក់បញ្ចូលនូវព័ត៌មានដូចជា សូចនាករ វិធីសាស្ត្រសម្រាប់ការប្រមូលព័ត៌មាន ការកំណត់រយៈពេល និងការប្រើប្រាស់ព័ត៌មាន។ កម្រងព័ត៌មានស្តីពីលទ្ធផល និង ដំណើរការ ត្រូវបានរៀបចំ។ ព័ត៌មានអំពីលទ្ធផលនឹងមានសារៈប្រយោជន៍ចំពោះការតាមដានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ នៃការវិនិយោគសាធារណៈនៅក្នុងផែនការសកម្មភាព ហើយនឹងត្រូវរាយការណ៍ជូនរដ្ឋាភិបាល និងដៃគូម្ចាស់ជំនួយក៏ដូចជាអ្នកអនុវត្តគម្រោងខ្លួនឯងផ្ទាល់ផងដែរ។ ម្យ៉ាងវិញទៀត ព័ត៌មានអំពីដំណើរការ សំដៅចំពោះ "តើសកម្មភាពជោគជ័យ និង មិនជោគជ័យ ត្រូវបានអនុវត្តដោយរបៀបណា" និង មេរៀននិងបទពិសោធន៍ពីអ្នកអនុវត្តន៍គម្រោងផែនការសកម្មភាពផ្សេងៗគ្នា។ ព័ត៌មានប្រភេទនេះ នឹងត្រូវបានចែករំលែក "តាមខ្សែបណ្តោយ" ក្នុងចំណោមអ្នកពាក់ព័ន្ធ (សហគមន៍កសិកម្ម មន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន ។ល។) ហើយនឹងក្លាយជាផ្នែកមួយនៃការផ្តួចផ្តើម គ្រប់គ្រងចំណេះដឹងរបស់កម្មវិធី។ វិធីសាស្ត្រដោយមានការចូលរួមសម្រាប់ការត្រួតពិនិត្យ នឹងត្រូវបានអនុវត្ត ដើម្បីធានាឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ។

បុគ្គលិករបស់មន្ទីរកសិកម្ម នឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍តាមមូលដ្ឋាន អ្នកទទួលផល និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីត្រួតពិនិត្យនិងតាមដានលើផែនការសកម្មភាពនេះ។ ការវាយតម្លៃលើគម្រោងនានា គឺត្រូវការជំនួយពីខាងក្រៅ។

## ២. កិច្ចសហការអន្តរស្ថាប័នក្នុងការអនុវត្តផែនការ

ស្ថាប័នរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិសំខាន់ៗមួយចំនួន ដែលធ្វើការងារគ្រប់គ្រងគ្រោះមហន្តរាយ ការបន្សាំការប្រែប្រួលអាកាសធាតុ និងការងារកសិកម្ម គឺជាអ្នកពាក់ព័ន្ធយ៉ាងសំខាន់ក្នុងការអនុវត្តរួមគ្នានូវផែនការសកម្មភាពនេះ។

### ២.១. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត គឺជារចនាសម្ព័ន្ធថ្នាក់ខេត្តរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ គណៈកម្មាធិការនេះមានអភិបាលនៃគណៈអភិបាលខេត្តជាប្រធាន អភិបាលរងខេត្តជាអនុប្រធាន និងប្រធានមន្ទីរ និងអង្គភាពខេត្តទាំងអស់ជាសមាជិក។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ផ្តល់ការដឹកនាំ និងការសម្របសម្រួលជារួម សម្រាប់ការកាត់បន្ថយនិងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅក្នុងខេត្ត។ រចនាសម្ព័ន្ធនៃការគ្រប់គ្រងគ្រោះមហន្តរាយ មានរហូតដល់ថ្នាក់មូលដ្ឋាន មានដូចជា គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក/ក្រុង គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ/សង្កាត់ និងក្រុមគ្រប់គ្រងគ្រោះមហន្តរាយភូមិ។

### ២.២. មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ស្ពឺ

មន្ទីរធនធានទឹកនិងឧតុនិយម ដឹកនាំ និងគ្រប់គ្រងវិស័យធនធានទឹក និងឧតុនិយមនៅថ្នាក់ខេត្ត។ ការទទួលខុសត្រូវរបស់ស្ថាប័ននេះ មានទំនាក់ទំនងជិតស្និទ្ធទៅនឹងវិស័យកសិកម្មជាពិសេស ការងារប្រព័ន្ធធារាសាស្ត្រនិងឧតុនិយម។ យុទ្ធសាស្ត្រទឹកនិងកសិកម្ម ត្រូវបានរៀបចំឡើងដោយក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីគូសបញ្ជាក់អំពីវិស័យដែលក្រសួងទាំងពីរនេះ ត្រូវរួមគ្នាទទួលខុសត្រូវ លើទំនាក់ទំនងរវាងការប្រើប្រាស់និងការគ្រប់គ្រងទឹក សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការគ្រប់គ្រងដីកសិកម្ម កសិពាណិជ្ជកម្ម ការស្រាវជ្រាវ ការអប់រំ និងការផ្សព្វផ្សាយលើវិស័យកសិកម្ម។ យុទ្ធសាស្ត្រនេះរំលេចអំពីការសហការនៅថ្នាក់ក្រោមជាតិផងដែរ ជាពិសេសគឺថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន។

### ២.៣. អង្គការមិនមែនរដ្ឋាភិបាល

អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបាននិងកំពុងអនុវត្តសកម្មភាពការងារការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងខេត្តកំពង់ស្ពឺ។ ភាគច្រើននៃបណ្តាអង្គការមិនមែនរដ្ឋាភិបាលទាំងនោះមិនមានការិយាល័យ ឬ ការិយាល័យតំណាង

របស់ខ្លួននៅក្នុងខេត្តទេ គឺគេអនុវត្តគម្រោង ឬសកម្មដោយផ្ទាល់ពីការិយាល័យកណ្តាល ដោយសហការជាមួយមន្ទីរ ការិយាល័យស្រុក ឬក្រុមប្រឹក្សាឃុំ ឬជាមួយអ្នកទទួលផលដោយផ្ទាល់។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលកំពុងអនុវត្តនៅខេត្តកំពង់ស្ពឺ លើការងារកសិកម្ម មុខរបរ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមមានដូចជា ៖ អង្គការជីវិតថ្លៃថ្នូរ អង្គការទស្សនៈពិភពលោក មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍកសិកម្មកម្ពុជា អង្គការស្រែខ្មែរ អង្គការចំរើនជាតិ អង្គការភាពជាដៃគូអភិវឌ្ឍន៍កម្ពុជា និងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា ។ល។

## ឧបសម្ព័ន្ធទី ១ ៖ ផែនការសកម្មភាពសម្រាប់ ២០១៤ - ២០១៨

| សកម្មភាពយុទ្ធសាស្ត្រ | សកម្មភាពជាក់លាក់ ២០១៤-២០១៨ | សូចនាករវាស់វែង | ពេលវេលាអនុវត្តន៍ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
| គោលដៅ ៖ ដើម្បីពង្រឹងសមត្ថភាព និងកសាងភាពធន់របស់កសិករនិងសហគមន៍ ទៅនឹងការគំរាមកំហែង ពីគ្រោះមហន្តរាយដែលប៉ះពាល់ដល់វិស័យកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ | | | | | | | |
| អាទិភាពទី ១ ៖ ពង្រឹងសមត្ថភាពស្ថាប័ននិងបច្ចេកទេស និងបង្កើនយន្តការសម្របសម្រួលសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម | | | | | | | |
| ១.១ ពង្រឹងយន្តការស្ថាប័នសម្រាប់ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងស្ថាប័នជំនាញ និងអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្ត សម្រាប់ការអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | | | | | | | |
| ១.១.១ បង្កើតក្រុមការងារបង្គោលនៅក្នុងមន្ទីរកសិកម្មខេត្ត ដើម្បីសម្របសម្រួលនិងណែនាំដល់មន្ទីរលើការងារ DRR និង CCA និងដើម្បីអនុវត្តការងារបច្ចេកទេសពាក់ព័ន្ធ | ១.១.១.១ បង្កើតគណៈកម្មធិការអចិន្ត្រៃយ៍ និងក្រុមការងារបច្ចេកទេស ដើម្បីផ្តល់ការណែនាំលើផែនការសកម្មភាពសម្រាប់ការអនុវត្ត DRR | ជនបង្គោល និងអង្គភាពបង្គោលត្រូវបានជ្រើសតាំងដោយមានលក្ខខណ្ឌការងារច្បាស់លាស់ | X | X | | | |
| | ១.១.១.២ លើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ នៅក្នុងការងារ DRR និង CCAក្នុងមន្ទីរកសិកម្ម | ចំនួនស្ត្រីមានតួនាទីក្នុងការសម្រេចចិត្ត | X | X | X | X | X |
| | ១.១.១.៣ ផ្តល់សម្ភារ និងភស្តុភារសម្រាប់គាំទ្រដល់យន្តការសម្របសម្រួលសម្រាប់ DRR និង CCA | លេខាធិការដ្ឋានដំណើរការបាន ពេលមានគ្រោះមហន្តរាយ | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.១.២ បង្កើត និងពង្រឹងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួលអន្តរស្ថាប័ន និងការផ្លាស់ប្តូរព័ត៌មាន ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ លើការងារ DRR និង CCA នៅគ្រប់កម្រិត | ១.១.២.១ អនុវត្តគោលនយោបាយ ផែនការ និងគោលការ សម្រាប់ការដាក់បញ្ចូលការងារ DRR និង CCA ក្នុងផលិតកម្មដំណាំ និងផលិតកម្មសត្វ | ចំនួនគម្រោងដែលបានដាក់បញ្ចូល DRR និងCCA | X | X | X | X | X |
| | ១.១.២.២ បង្កើតបណ្តាញទំនាក់ទំនងជាមួយមន្ទីរ ធ.ទ.ឧ ខេត្ត ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើការងារគ្រប់គ្រងធនធានទឹក សម្រាប់ការកសាងផែនការទាក់ទងនឹងDRR និង CCA | គណៈកម្មាធិការអន្តរស្ថាប័ន ត្រូវបានបង្កើតឡើង | X | X | X | X | X |
| | ១.១.២.៣ ចូលរួមជាសមាជិកក្នុងក្រុមការងារបច្ចេកទេស នៅក្នុងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ សម្រាប់ការសម្របសម្រួលលើបច្ចេកទេសកសិកម្ម | តំណាងរបស់មន្ទីរកសិកម្មនៅក្នុងក្រុមការងារបច្ចេកទេស | X | X | X | X | X |
| | ១.១.២.៤ សម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមតាមមូលដ្ឋាន ដែលធ្វើការលើវិស័យកសិកម្ម ដើម្បីបញ្ជ្រាប DRR និង CCA ទៅក្នុងផែនការនិងកម្មវិធីរបស់ពួកគេ | ចំនួនគម្រោងដែលបានដាក់បញ្ចូល DRR និងCCA | X | X | X | X | X |
| **១.២ ពង្រឹងសមត្ថភាពស្ថាប័នរបស់មន្ទីរកសិកម្ម និងការិយាល័យកសិកម្មស្រុក សម្រាប់ការអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព** | | | | | | | |
| ១.២.១ ពង្រឹងសមត្ថភាពផ្នែកជំនាញបច្ចេកទេសរបស់មន្ទីរកសិកម្ម ដើម្បីឆ្លើយតបនឹងការងារ DRR និង CCA | ១.២.១.១ ធ្វើបច្ចុប្បន្នភាពតួនាទី របស់បុគ្គលិកមួយចំនួនដោយដាក់បញ្ចូលនូវការទទួលខុសត្រូវលើការងារ DRR និង CCA | កែសម្រួលលក្ខខណ្ឌការងាររបស់បុគ្គលិកបច្ចេកទេសដោយដាក់បញ្ចូលកាតព្វកិច្ច DRR និង CCA | X | X | X | X | X |
| | ១.២.១.២ បង្កើតក្រុមបណ្តុះបណ្តាល ស្តីពី DRR និង CCA និងកសាងសមត្ថភាព និងបំពាក់ធនធាន និងចំណេះដឹងគ្រប់គ្រាន់ សម្រាប់ការបណ្តុះបណ្តាល | ក្រុមបណ្តុះបណ្តាលត្រូវបានបង្កើតឡើង | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.២.១.៣ រៀបចំមេរៀនបណ្តុះបណ្តាលស្តីពី DRR និង CCA ឲ្យស្របតាមតម្រូវការ និងលក្ខខណ្ឌ ភូមិសាស្ត្រនៃកសិកម្ម នៅក្នុងខេត្ត និងរៀបចំយុទ្ធសាស្ត្របណ្តុះបណ្តាលដោយប្រសិទ្ធភាព | មេរៀនវគ្គបណ្តុះបណ្តាល អាចរកបាន | X | X | X | | |
| | ១.២.១.៤ បណ្តុះបណ្តាលដល់ការិយាល័យកសិកម្មស្រុក និងឃុំមួយចំនួនដែលប្រឈមនឹងគ្រោះរាំងស្ងួត ស្តីពី កសិកម្មធន់នឹងគ្រោះមហន្តរាយ និងDRR និង CCA នៅក្នុងវិស័យកសិកម្ម | ចំនួនវគ្គបណ្តុះបណ្តាល | | X | X | X | X |
| ១.២.២ ពង្រឹងការស្រាវជ្រាវតាមមូលដ្ឋាន(ស្រាវជ្រាវផ្សព្វផ្សាយ) ដើម្បីគាំទ្រដល់ DRR និង CCA ក្នុងវិស័យកសិកម្ម | ១.២.២.១ រៀបចំការស្រាវជ្រាវ និងការបង្ហាញតាមមូលដ្ឋាន ស្តីពីប្រព័ន្ធ និងបច្ចេកទេសកសិកម្មធន់នឹងមុខសញ្ញាគ្រោះថ្នាក់(រាំងស្ងួត ទឹកជំនន់ សមាសភាគចង្រៃនិងជំងឺ) ឲ្យស្របតាមតំបន់ភូមិសាស្ត្រផ្សេងៗគ្នា នៅក្នុងខេត្ត | ចំនួនស្រែបង្ហាញពីបច្ចេកទេស និងប្រព័ន្ធកសិកម្មធន់នឹងមុខសញ្ញាគ្រោះថ្នាក់ | X | X | X | X | X |
| | ១.២.២.២ រៀបចំការស្រាវជ្រាវ និងការបង្ហាញពីបច្ចេកទេសជីវសុវត្ថភាពក្នុងការចិញ្ចឹមសត្វ | ចំនួនការស្រាវជ្រាវ និងការបង្ហាញពីការចិញ្ចឹមសត្វ | X | X | X | X | X |
| អាទិភាពទី ២៖ ជំរុញ និងពង្រឹងប្រព័ន្ធប្រកាសឲ្យដឹងមុនសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដោយភាពសកម្ម | | | | | | | |
| ២.១ ជំរុញ និងគាំទ្រការផ្លាស់ប្តូរទិន្នន័យសម្រាប់សេវាកម្មអាកាសធាតុ និងព័ត៌មានប្រកាសឲ្យដឹងមុនក្នុងវិស័យកសិកម្ម ជាមួយមន្ទីរ និងអ្នកពាក់ព័ន្ធនានា | | | | | | | |
| ២.១.១ បង្កើត និងកែលម្អបណ្តាញទំនាក់ទំនងជាមួយស្ថាប័នក្រោមឱវាទក្រសួងធនធានទឹកនិងឧតុនិយម អគ្គនាយកដ្ឋានចំណុះក្រសួង | ២.១.១.១ បង្កើតបណ្តាញទ្វេភាគីជាមួយមន្ទីរ ធ.ទ.ឧ សម្រាប់ការផ្លាស់ប្តូរទិន្នន័យ និងព័ត៌មានអាកាសធាតុ និងធាតុអាកាសជាប្រចាំដែលសមស្របទៅតាមតម្រូវការរបស់វិស័យកសិកម្ម | បណ្តាញអន្តរស្ថាប័នត្រូវបានបង្កើតឡើង | X | X | X | X | X |
| | ២.១.១.២ បង្កើតបណ្តាញអន្តរស្ថាប័នជាមួយអគ្គនាយកដ្ឋាននានារបស់ក្រសួងក.ស.ក ជាពិសេស អ.ន.ក និងនាយកដ្ឋានផលិតកម្ម | បណ្តាញអន្តរស្ថាប័នត្រូវបានបង្កើតឡើង | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់និង នេសាទ និងស្ថាប័នផ្សេងៗ ទៀត សម្រាប់ការផ្លាស់ប្តូរ ព័ត៌មានប្រកាសឲ្យដឹងមុនស្រប ទៅតាមតម្រូវការរបស់កសិករ | និងបសុព្យាបាល ដើម្បីទទួលបានព្រឹត្តិបត្រព័ត៌មានអាកាសធាតុ តម្លៃទីផ្សារសម្រាប់ផលិតផលកសិកម្ម ការគ្រប់គ្រងសមាសភាពចង្រៃ និងព័ត៌មានពីការផ្ទុះឡើងនៃជំងឺរាតត្បាត ក្នុងវិស័យកសិកម្ម | | | | | | |
| | ២.១.១.៣ បង្កើតបណ្តាញអន្តរស្ថាប័នជាមួយមន្ទីរព័ត៌មានខេត្ត និង ស្ថានីយវិទ្យុប្រចាំខេត្ត សម្រាប់ការផ្សព្វផ្សាយពីគ្រោះមហន្តរាយ ដែលប៉ះពាល់ដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | បណ្តាញអន្តរស្ថាប័ន ត្រូវបានបង្កើតឡើង | X | X | X | X | X |
| **២.២. ជំរុញការផលិតព័ត៌មានអាកាសធាតុជាក់លាក់ និងព័ត៌មានប្រកាសឲ្យដឹងមុន ដែលកែសម្រួលទៅតាមតម្រូវការក្នុងវិស័យកសិកម្ម** | | | | | | | |
| ២.២.១ ជំរុញការកែសម្រួល និងបកប្រែព័ត៌មានកសិឧតុនិយម ដែលទទួលបាន ពី អ.ន.ក និងក្រសួង ធ.ទ.ឧ សមស្របទៅតាមស្ថានភាពភូមិសាស្ត្ររបស់ខេត្តកំពង់ស្ពឺ | ២.២.១.១ បង្កើត និងកសាងសមត្ថភាពរបស់ក្រុមការងារកសិឧតុនិយមនៅក្នុងមន្ទីរកសិកម្ម និងបកប្រែព័ត៌មានអាកាសធាតុ និងឧតុនិយម ដែលទទួលបានពីថ្នាក់ជាតិ ឲ្យទៅជាការណែនាំសម្រាប់ការប្រើប្រាស់ក្នុងវិស័យកសិកម្មនៅក្នុងខេត្តកំពង់ស្ពឺ | ក្រុមជំនាញបកប្រែ ទិន្នន័យកសិឧតុនិយម ត្រូវបានបង្កើតឡើង ដោយមានលក្ខខណ្ឌការងារច្បាស់លាស់ | | X | X | X | X |
| | ២.២.១.២ ផលិតព្រឹត្តិបត្រព័ត៌មានប្រកាសឲ្យដឹងមុន ព័ត៌មានអាកាសធាតុនិងព័ត៌មានធាតុអាកាសសម្រាប់ខេត្តកំពង់ស្ពឺ សម្រាប់ជាឧបករណ៍ជំនួយស្មារតីក្នុងផលិតកម្មសត្វនិងដំណាំ និង សម្រាប់ការកសាងផែនការ ដោយស្របតាមប្រក្រតិទិនដាំដុះ | ទស្សនរបស់កសិករ ចំពោះព័ត៌មានកសិឧតុនិយម | | X | X | X | X |
| ២.២.២ ផលិត និងផ្សព្វផ្សាយព័ត៌មានពីតម្លៃទីផ្សារកសិផលជាប្រចាំ | ២.២.២.១ បង្កើតក្រុមការងារបច្ចេកទេស ដើម្បីប្រមូលទិន្នន័យ និងព័ត៌មានតម្លៃទីផ្សារនៃកសិផល | ក្រុមការងារបច្ចេកទេស ត្រូវបានបង្កើតឡើង ដោយមានលក្ខខណ្ឌការងារច្បាស់លាស់ | | X | X | X | X |
| | ២.២.២.២ ផ្តល់ព័ត៌មានពីតម្លៃកសិផលនៅលើទីផ្សារ ដល់ អ.ន.ក ដើម្បីចូលរួមក្នុងការផលិតព្រឹត្តិបត្រតម្លៃកសិផលលើទីផ្សារ | ព្រឹត្តិបត្រព័ត៌មានទីផ្សារ អាចរកបាន និងអាចប្រើប្រាស់បានដោយ | | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | កសិករ | | | | | |
| ២.២.៣ បង្កើត និងពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងតាមដានជំងឺសត្វ និងសមាសភាគចង្រៃ | ២.២.៣.១ កសាងសមត្ថភាពដល់ក្រុមមន្ត្រីបសុពេទ្យខេត្ត ដើម្បីកំណត់ តាមដានការផ្ទុះឡើងជាបឋមនៃជំងឺសត្វ | ចំនួនវគ្គបណ្តុះបណ្តាលស្តីពីការតាមដានជំងឺសត្វ | X | X | X | X | X |
| | ២.២.៣.២ កសាងសមត្ថភាពដល់ក្រុមមន្ត្រីមន្ទីរកសិកម្មខេត្តដើម្បីកំណត់ និងតាមដានការផ្ទុះឡើងជាបឋមនៃ សមាសភាគចង្រៃ (មមាចត្នោត កណ្តូប កណ្តុរ ។ល។) | ចំនួនវគ្គបណ្តុះបណ្តាលស្តីពីការតាមដានសមាសភាគចង្រៃ | X | X | X | X | X |
| | ២.២.៣.៣ កសាងសមត្ថភាពដល់ភ្នាក់ងារសុខភាពសត្វភូមិ និងតាមដានកម្រិតមូលដ្ឋាន និងរាយការណ៍ពីជំងឺ ការផ្ទុះឡើងពីជំងឺសត្វ (ផ្តាសាយបក្សី ញូកាស ប៉េស្តជ្រូក អាសន្នរោគ បូសខ្យល់ សារទឹក អុតក្តាម ។ល។) | ចំនួនវគ្គបណ្តុះបណ្តាលដល់ភ្នាក់ងារសុខភាពសត្វភូមិពីការតាមដានជំងឺសត្វ | X | X | X | X | X |
| ២.២.៤ គាំទ្រការរៀបចំផែនទីលម្អិតពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងហានិភ័យ នៅកម្រិតខេត្ត និងស្រុក | ២.២.៤.១ រៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ និងភាពងាយរងគ្រោះជាក់លាក់សម្រាប់វិស័យកសិកម្ម និងចែករំលែកព័ត៌មានសម្រាប់ផែនការបន្ស៊ាំ និងផែនការកាត់បន្ថយហានិភ័យ កម្រិតខេត្ត និងស្រុក | ផែនទីមុខសញ្ញាគ្រោះថ្នាក់អាចរកបានសម្រាប់វិស័យកសិកម្មក្នុងខេត្តកំពង់ស្ពឺ | X | X | | | |
| | ២.២.៤.២ រៀបចំការប៉ាន់ប្រមាណហានិភ័យ និងផែនទីភាពងាយរងគ្រោះ ជាពិសេសសម្រាប់ផលិតកម្មជ្រូក និងផលិតកម្មបក្សី ក្នុងស្រុកសំរោងទង គងពិសី បសេដ្ឋ ច្បារមន និងភ្នំស្រួច និងប្រើប្រាស់ជាឧបករណ៍ជំនួយស្មារតីសម្រាប់កសិកម្មខ្នាតតូច និងមធ្យម | ផែនទីភាពងាយរងគ្រោះនៃជំងឺសត្វអាចរកបាន | X | X | X | | |
| | ២.២.៤.៣ រៀបចំការសិក្សាស្តីពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត លើការអនុវត្តជីវសុវត្ថិភាពនៅក្នុងកសិដ្ឋានខ្នាតតូច និងមធ្យម (កសិដ្ឋានចិញ្ចឹមជ្រូក/មាន់) និងប្រើប្រាស់សម្រាប់ជាឧបករណ៍បញ្ជ្រាប និងពង្រឹងការអនុវត្តជីវសុវត្ថិភាព និងការកំណត់ការរីក | លទ្ធផលនៃការវិភាគអាចរកបានសម្រាប់ធ្វើការសម្រេចចិត្តក្នុងកម្រិតផ្សេងៗគ្នា | X | | | | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សាយភាយនៃជំងឺ | | | | | | |
| | ២.២.៤.៤ រៀបចំ និងផលិតសាកល្បងនូវប្រក្រតិទិនដាំដុះ សម្រាប់តំបន់ដែលដាំតែស្រូវ នៅក្នុងខេត្តកំពង់ស្ពឺ | ប្រក្រតិទិនដាំដុះត្រូវ សម្រាប់ខេត្តកំពង់ស្ពឺ អាចរកបាន | X | X | | | |
| | ២.២.៤.៥ កំណត់តំបន់ដាំដុះ និងប្រើប្រាស់សម្រាប់ការផលិត ឧបករណ៍បណ្តុះបណ្តាលជាក់លាក់ និងសម្រាប់ជាឧបករណ៍ជំនួយស្មារតីក្នុង ការធ្វើផែនការដាំដុះ | ផែនទីកំណត់តំបន់ ដាំដុះសម្រាប់ខេត្ត កំពង់ស្ពឺអាចរកបាន | X | X | X | | |
| **២.៣ ពង្រឹងបណ្តាញទំនាក់ទំនង សម្រាប់ការផ្សព្វផ្សាយព័ត៌មានទៅដល់កសិករ និងសហគមន៍អាស្រ័យលើកសិកម្ម** | | | | | | | |
| ២.៣.១ ពង្រឹងយន្តការទំនាក់ទំនង ដើម្បីជំរុញព័ត៌មាន ប្រកាសឲ្យដឹងមុនឲ្យទាន់ពេលវេលា និងអាចជឿជាក់បាន | ២.៣.១.១ បង្កើតជាមជ្ឈមណ្ឌលព័ត៌មាននៅក្នុងមន្ទីរកសិកម្ម និង បំពាក់ធនធានគ្រប់គ្រាន់ដើម្បីប្រមូល និងទទួលព័ត៌មានពីមូលដ្ឋាន (មុខសញ្ញាគ្រោះថ្នាក់៖ ទឹកជំនន់ រាំងស្ងួត សមាសភាគចង្រៃ និងជំងឺ) សម្រាប់ការ កសាងផែនការ និងប្រតិបត្តិការនានា | ប្រកាសរបស់មន្ទីរស្តីពី ការរៀបចំ និងប្រព្រឹត្ត ទៅនៃមជ្ឈមណ្ឌល ព័ត៌មាន | | | X | X | X |
| | ២.៣.២.២ បង្កើតវេទិកា បណ្តាញរវាងមន្ទីរនិងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចែករំលែក និងធ្វើបច្ចុប្បន្នភាពព័ត៌មានពីមុខសញ្ញា គ្រោះថ្នាក់ប៉ះពាល់លើវិស័យកសិកម្ម | បណ្តាញវេទិកាត្រូវបាន បង្កើតឡើង | X | X | X | X | X |
| | ២.៣.២.៣ ផ្សព្វផ្សាយជាប្រចាំព័ត៌មានអាកាសធាតុ និងព័ត៌មាន ប្រកាសឲ្យដឹងមុន តាមរយៈភ្នាក់ងារសុខភាពសត្វភូមិដែលមាន ស្រាប់ អង្គការមិនមែនរដ្ឋាភិ- បាល អ្នកផ្សព្វផ្សាយ ជាពិសេសសម្រាប់តំបន់ប្រឈមនឹងមុខសញ្ញា គ្រោះថ្នាក់នៃគ្រោះមហន្តរាយ | ទស្សនរបស់កសិករលើ សេវាកម្មផ្សព្វផ្សាយ កសិកម្ម | X | X | X | X | X |
| ២.៣.២ បង្កើនសមត្ថភាពរបស់ការិយាល័យ-ផ្នែកផ្សព្វផ្សាយ នៅកម្រិតមន្ទីរ និងកម្រិតភូមិ | ២.៣.២.១ ពង្រឹងសមត្ថភាពផ្នែកផ្សព្វផ្សាយរបស់មន្ទីរកសិកម្ម ដើម្បីផ្សព្វផ្សាយព័ត៌មានបច្ចេកទេស និងព័ត៌មានប្រកាសឲ្យដឹងមុន | កម្រិតនៃការពេញចិត្ត របស់កសិករចំពោះ សេវាកម្មផ្សព្វផ្សាយ | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សម្រាប់ទំនាក់ទំនងមានប្រសិទ្ធភាព | | កសិកម្ម | | | | | |
| | ២.៣.២.២ បង្កើនសមត្ថភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិ និងបណ្តុះបណ្តាលពួកគេឲ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ និងសាកល្បងនៅក្នុងស្រុកសំរោងទង និងស្រុកគងពិសី | កម្រិតនៃការពេញចិត្តរបស់កសិករចំពោះសេវាកម្មផ្សព្វផ្សាយកសិកម្ម | X | X | X | X | X |
| **អាទិភាពទី ៣៖ ពង្រឹងការគ្រប់គ្រងចំណេះដឹង និងគំនិតផ្តួចផ្តើមថ្មី ក្នុងការគាំទ្រដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម** | | | | | | | |
| **៣.១ ពង្រឹង និងឬភ្ជាប់ទិន្នន័យទាក់ទងនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីរៀបចំផែនការ និងការសម្រេចចិត្តឲ្យកាន់តែប្រសើរឡើង** | | | | | | | |
| ៣.១.១ គាំទ្រទៅដល់ការប្រមូលទិន្នន័យថ្មីជាលក្ខណៈប្រព័ន្ធ និងបង្កើនការទទួលបានព័ត៌មាន និងទិន្នន័យមានស្រាប់ទាក់ទងទៅនឹង DRR និង CCA ក្នុង វិស័យកសិកម្ម | ៣.១.១.១ ធ្វើបច្ចុប្បន្នភាពជាប្រចាំលើទិន្នន័យកសិកម្ម ក្នុងបរិបទនៃការប្រើប្រាស់សម្រាប់ DRR និង CCA | ទិន្នន័យកសិកម្មអាចរកបាន | X | X | X | X | X |
| | ៣.១.១.២ ផ្សាភ្ជាប់បណ្តាញទិន្នន័យទៅនឹងប្រព័ន្ធទិន្នន័យថ្នាក់ជាតិ | ទិន្នន័យកសិកម្មថ្នាក់ជាតិនិងថ្នាក់ខេត្តអាចរកបាន | X | X | X | X | X |

| ៣.២ បង្កើនមូលដ្ឋាន ចំណេះដឹង និងជំរុញគំនិតផ្តួចផ្តើមថ្មីសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម ដោយរួមបញ្ចូលការចងក្រងនិងផ្សព្វផ្សាយបច្ចេកទេសល្អៗ | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.២.១ ជំរុញការបង្កើតសាលារៀនស្រែកសិករ និងស្រែបង្ហាញ ដើម្បីផ្សព្វផ្សាយចំណេះដឹង និងជម្រើសបច្ចេកទេសល្អក្នុងការងារ DRR និង CCA | ៣.២.១.១ សម្របសម្រួលក្នុងការបង្កើតសាលារៀនស្រែកសិករ នៅក្នុងតំបន់ប្រឈមនឹងគ្រោះមហន្តរាយ | ចំនួនសាលារៀនស្រែកសិករដែលបានបង្កើត | X | X | X | X | X |
| | ៣.២.១.២ ផ្សព្វផ្សាយព័ត៌មានបច្ចេកទេសដល់កសិករ ស្តីពី DRR និង CCA | កម្រិតនៃការពេញចិត្តរបស់កសិករចំពោះសេវាកម្មផ្សព្វផ្សាយកសិកម្ម | X | X | X | X | X |
| | ៣.២.១.៣ ផ្តល់វគ្គបណ្តុះបណ្តាលដល់កសិករគំរូស្តីពីកសិកម្មធន់នឹងគ្រោះមហន្តរាយ | ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំ | X | X | X | X | X |
| ៣.២.២ រៀបចំ និងផ្សព្វផ្សាយសៀវភៅបច្ចេកទេសកសិកម្មស្តីពីដំណាំដែលបានណែនាំ និង ការអនុវត្តការគ្រប់គ្រងដីប្រកបដោយនិរន្តរភាព ក្នុងបរិបទ DRR និង CCA | ៣.២.២.១ កត់ត្រា និងចងក្រងសៀវភៅបច្ចេកទេស សម្រាប់ DRR និង CCA ដោយផ្តោតលើដំណាំជាក់លាក់មួយចំនួន (ស្រូវ សណ្តែក ដំឡូងមី) សម្រាប់កសិករតូចតាច និងមធ្យម | សៀវភៅបច្ចេកទេសកសិកម្មសមស្របអាចរកបាន | X | X | X | X | X |
| | ៣.២.២.២ បោះពុម្ព និងចែកចាយសៀវភៅ និងសម្ភារឧបទ្ទេស (សៀវភៅបច្ចេកទេស អត្ថបទស្តីពីបទពិសោធន៍ល្អ ផ្ទាំងរូបភាព...) ទៅដល់កសិករតូចតាច និងមធ្យម | សម្ភារឧបទ្ទេសកសិកម្មសមស្របអាចរកបាន | | | X | X | X |
| ៣.២.៣ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រកសាងសមត្ថភាព និងអនុវត្តបច្ចេកទេសល្អ សម្រាប់ DRR ក្នុងវិស័យកសិកម្ម | ៣.២.៣.១ បណ្តុះបណ្តាលដល់អ្នកផ្សព្វផ្សាយនិងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើនចំណេះដឹងជាមូលដ្ឋានផ្អែកលើបច្ចេកទេសល្អៗ ស្តីពី DRR | ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំ | X | X | X | X | X |
| | ៣.២.៣.២ គាំទ្រដល់ការអនុវត្ត សាកល្បង និងវាយតម្លៃនៃបច្ចេកទេសល្អស្តីពី DRR ក្នុងវិស័យកសិកម្ម | ចំនួនបច្ចេកទេសល្អដែលបានសាកល្បង | | X | X | X | X |

| ៣.៣ បង្កើនការយល់ដឹង និងទំនាក់ទំនងសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.៣.១ រៀបចំយុទ្ធនាការបង្កើនការយល់ដឹងនិងកម្មវិធីបណ្តុះបណ្តាលស្តីពីបទពិសោធន៍ និងបច្ចេកទេសល្អអំពីDRR និង CCA | ៣.៣.១.១ រៀបចំការសិក្សា និងប៉ាន់ប្រមាណពីតម្រូវការជាលក្ខណៈតំណាង នៅក្នុងស្រុក ឃុំដែលបានជ្រើសរើស ដើម្បីកំណត់ពីកង្វះខាតព័ត៌មាន និងតម្រូវការ របស់កសិករទាក់ទងទៅនឹង DRR និងផលប៉ះពាល់ផ្នែកសង្គមសេដ្ឋកិច្ចដោយគ្រោះមហន្តរាយ ក្នុងវិស័យកសិកម្ម | លទ្ធផលនៃការវិភាគអាចរកបានសម្រាប់ធ្វើការសម្រេចចិត្តក្នុងកម្រិតផ្សេងៗគ្នា | X | X | X | | |
| | ៣.៣.១.២ រៀបចំកម្មវិធីបង្កើនការយល់ដឹងតាមមូលដ្ឋាន និងផ្សព្វផ្សាយពីបទពិសោធន៍ និងបច្ចេកទេសល្អៗស្តីពីDRR និង CCA ក្នុងវិស័យកសិកម្ម តាមរយៈបណ្តាញដែលមានស្រាប់ (អ្នកផ្សព្វផ្សាយ ភ្នាក់ងារសុខភាពសត្វភូមិ កសិករគំរូ។ល។) និងតាមរយៈសកម្មភាពនៅតាមសហគមន៍ (ស្រែបង្ហាញ ទិវាស្រែកសិករ) | ចំនួនកម្មវិធីបង្កើនការយល់ដឹងដែលបានរៀបចំ | X | X | X | X | X |
| | ៣.៣.១.៣ ផ្សព្វផ្សាយព្រឹត្តិបត្រកសិឧតុនិយម ដែលផលិតដោយ អ.ន.ក តាមរយៈបណ្តាញដែលមានស្រាប់ (អ្នកផ្សព្វផ្សាយ ភ្នាក់ងារសុខភាពសត្វភូមិ កសិករគំរូ។ល។) | ចំនួនសហគមន៍ដែលទទួលបានព័ត៌មានជាប្រចាំ | | X | X | X | X |
| ៣.៣.២ ផ្សាភ្ជាប់កសិករទៅគោលនយោបាយថ្នាក់ជាតិ ដើម្បីធ្វើការតស៊ូមតិ និងបង្កើនការយល់ដឹងពី DRR និង CCA | ៣.៣.២.១ ផ្តល់ការគាំទ្របច្ចេកទេសដល់កសិករគំរូ និងគាំទ្រពួកគាត់ក្នុងការចូលរួមប្រឡងប្រណាំងកសិករគំរូថ្នាក់ជាតិ ស្តីពីបច្ចេកទេសកសិកម្មធន់ | ចំនួនកសិករនៅក្នុងខេត្តដែលទទួលចូលរួមក្នុងការប្រកួតថ្នាក់ជាតិ | X | X | X | X | X |
| | ៣.៣.២.២ រៀបចំវេទិកាថ្នាក់ខេត្តសម្រាប់ការប្រឡងប្រណាំងកសិករស្តីពីការអនុវត្តន៍ល្អ ក្នុងការងារ DRR និង CCA | វេទិកាកសិកម្មរៀបចំជារៀងរាល់ឆ្នាំ | X | X | X | X | X |
| | ៣.៣.២.៣ លើកទឹកចិត្តដល់ទស្សនកិច្ចសិក្សាសម្រាប់កសិករ | ចំនួនទស្សនកិច្ចសិក្សាដែលបានរៀបចំ | X | X | X | X | X |

## អាទិភាពទី ៤៖ កាត់បន្ថយភាពងាយរងគ្រោះតាមរយៈការបង្កើនជម្រើសបច្ចេកទេសក្នុងវិស័យកសិកម្ម និងការលើកកំពស់ដំណើរការនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដោយមានការចូលរួមពីសហគមន៍

### ៤.១ ជំរុញប្រព័ន្ធកសិកម្មចម្រុះ និងពិពិធកម្មដំណាំ ដើម្បីកសាងភាពធន់របស់សហគមន៍កសិកម្មទៅនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤.១.១ លើកទឹកចិត្តការអនុវត្តបង្កុំបច្ចេកទេសដាំដំណាំ (ពិពិធកម្មដំណាំ ដំណាំឆ្លាស់ ដំណាំចម្រុះ និងដំណាំគ្របដី) ដើម្បីកសាងភាពធន់ក្នុងវិស័យកសិកម្ម | ៤.១.១.១ ដោយសហការជាមួយ អ.ន.ក រៀបចំកញ្ចប់វគ្គបណ្តុះបណ្តាលសម្រាប់ពិពិធកម្មដំណាំ និងប្រព័ន្ធដំណាំចម្រុះ សមស្របទៅនឹងស្ថានភាពរបស់ឃុំមួយចំនួនក្នុងខេត្តកំពង់ស្ពឺផ្អែកលើព័ត៌មានពីការកំណត់តំបន់ដាំដុះ | ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំ | X | X | X | | |
| | ៤.១.១.២ ផ្តល់វគ្គបណ្តុះបណ្តាលជាក់លាក់ស្តីពីបង្កុំបច្ចេកទេសកសិកម្ម (ពិពិធកម្មដំណាំ ដំណាំឆ្លាស់ ដំណាំចម្រុះ និងដំណាំគម្របដី) សម្រាប់ឃុំគោលដៅមួយចំនួន ដែលបានកំណត់ផ្អែកលើព័ត៌មានពីការកំណត់តំបន់ដាំដុះ | ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំ | X | X | X | X | X |
| | ៤.១.១.៣ លើកទឹកចិត្តសម្រាប់ការដាំដំណាំក្រោយរដូវវស្សា (ក្រោយប្រមូលផល) | ចំនួនកសិករអនុវត្តបច្ចេកទេស | X | X | X | X | X |
| | ៤.១.១.៤ ជំរុញកសិកម្មចម្រុះជាលក្ខណៈគ្រួសារ | ចំនួនកសិករអនុវត្តបច្ចេកទេស | X | X | X | X | X |
| | ៤.១.១.៥ មិនលើកទឹកចិត្តដល់ការអនុវត្តឯកវប្បកម្មកសិកម្ម ដើម្បីកាត់បន្ថយខិនភាពដី | ភាគរយនៃកសិករដែលអនុវត្តឯកវប្បកម្មដំណាំ | X | X | X | X | X |
| ៤.១.២ លើកទឹកចិត្តដល់ការអនុវត្តប្រព័ន្ធកសិកម្មចម្រុះដំណាំ-សត្វ/វុក្ខកម្ម | ៤.១.២.១ លើកទឹកចិត្តដល់ការអនុវត្តប្រព័ន្ធស្រូវ-ត្រី និងសាកល្បងនៅក្នុងតំបន់ដែលកសិកម្មពឹងផ្អែកទឹកភ្លៀង | ចំនួនកសិករអនុវត្តបច្ចេកទេស | X | X | X | X | X |
| | ៤.១.២.២ លើកទឹកចិត្តដល់ការអនុវត្តប្រព័ន្ធ ស្រូវ-ទា និងសាកល្បងនៅក្នុងតំបន់ដែលប្រឈមនឹងទឹកជំនន់ | ចំនួនកសិករអនុវត្តបច្ចេកទេស | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៤.១.២.៣ លើកទឹកចិត្ត និងជំរុញគោលការណ៍កសិដ្ឋានពហុប្រយោជន៍ ទៅដល់កសិករខ្នាតតូច ដើម្បីកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត | ចំនួនកសិករអនុវត្តបច្ចេកទេស | X | X | X | X | X |
| | ៤.១.២.៤ ជំរុញប្រព័ន្ធកសិរុក្ខកម្ម នៅក្នុងស្រុក ភ្នំស្រួច ស្រុកថ្ពង ស្រុកឱរ៉ាល់ ស្រុកបសេដ្ឋ និងស្រុកគងពិសី | ចំនួនកសិករអនុវត្តបច្ចេកទេស | X | X | X | X | X |
| **៤.២ បង្កើនផលិតកម្មសត្វនៅគ្រប់កម្រិត** | | | | | | | |
| ៤.២.១ ជំរុញសមត្ថភាពបច្ចេកទេសលើការចិញ្ចឹម និង ផលិតកម្មសត្វនៅគ្រប់កម្រិត | ៤.២.១.១ ពង្រឹងសមត្ថភាពបច្ចេកទេសដល់ ពេទ្យសត្វ និងភ្នាក់ងារសុខភាពសត្វភូមិ លើផលិតកម្មសត្វ និងលើការអនុវត្តជីវសុវត្ថិភាព | ទស្សនៈរបស់កសិករចំពោះសេវាកម្មផ្សព្វផ្សាយកសិកម្ម | X | X | X | X | X |
| | ៤.២.១.២ ពង្រឹងយន្តការនានា ដើម្បីបង្កើនសមត្ថភាពដល់ភ្នាក់ងារចែកចាយ និងអ្នកលក់ដុំ លក់រាយបសុឱសថ និងចំណីសត្វនៅទូទាំងខេត្ត | ទស្សនៈរបស់កសិករចំពោះសេវាកម្មផ្សព្វផ្សាយកសិកម្ម | | X | X | X | |
| | ៤.២.១.៣ រៀបចំវគ្គបណ្តុះបណ្តាលពីការចិញ្ចឹមសត្វ (ជ្រូក និងបក្សី) ទៅដល់កសិករខ្នាតតូច | ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំ | | X | X | X | X |
| | ៤.២.១.៤ ជំរុញការតម្លើង សាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន ដើម្បីកាត់បន្ថយបំភាយឧស្ម័នផ្ទះកញ្ចក់ចេញពីការចិញ្ចឹមសត្វ | សមាមាត្រកសិករដែលមានឡជីវឧស្ម័ន | X | X | X | X | X |
| ៤.២.២ កសាង និងបង្កើនបរិយាកាសសមស្របសម្រាប់ការវិនិយោគលើផលិតកម្មសត្វនៅក្នុងខេត្តកំពង់ស្ពឺ | ៤.២.២.១ ផ្តល់ជំនួយបច្ចេកទេស និងការប្រឹក្សាយោបល់ស្តីពីផលិតកម្មសត្វដល់កសិករខ្នាតតូច និងមធ្យម | ទស្សនៈរបស់កសិករចំពោះសេវាកម្មផ្សព្វផ្សាយកសិកម្ម | | X | X | X | X |
| | ៤.២.២.២ ជំរុញ និងតស៊ូមតិជាមួយ ក.ស.ក ក្នុងការអនុវត្តវិធានចត្តាឡីស័ក និងការត្រួតពិនិត្យគុណភាព ជ្រូក និងផលិតផលដើមកំណើតបក្សីដែលនាំចូលពីបរទេស | ទស្សនៈរបស់កសិករចំពោះសេវាកម្មផ្សព្វផ្សាយកសិកម្ម | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤.២.៣ កំហិតការសាយភាយ និងរីករាលដាលនៃជំងឺសត្វ | ៤.២.៣.១ មិនលើកទឹកចិត្តចំពោះការចិញ្ចឹមសត្វដោយព្រលែង សម្រាប់ផលិតកម្មជ្រូក និងបក្សី | ចំនួនកសិករចិញ្ចឹមសត្វដោយព្រលែង | X | X | X | X | X |
| | ៤.២.៣.២ រៀបចំអធិការកិច្ចជាប្រចាំទៅដល់កសិដ្ឋានចិញ្ចឹមសត្វខ្នាតតូច និងមធ្យម ដើម្បីត្រួតពិនិត្យពីជីវសុវត្ថភាព និងសុខភាពសត្វ | ចំនួនអធិការកិច្ចប្រចាំខែដែលបានរៀបចំ | X | X | X | X | X |
| | ៤.២.៣.២ កសាងសមត្ថភាពរបស់ទីសត្តឃាតពីអនាម័យ និងវិធានជីវសុវត្ថិភាព | ទស្សនៈរបស់កសិករចំពោះសេវាកម្មផ្សព្វផ្សាយកសិកម្ម | X | X | X | X | X |
| | ៤.២.៣.៣ រៀបចំអធិការកិច្ចជាប្រចាំទៅដល់ទីសត្តឃាត ដើម្បីកំហិតការសាយភាយ និងរីករាលដាលនៃជំងឺ | ចំនួនអធិការកិច្ចប្រចាំខែដែលបានរៀបចំ | X | X | X | X | X |
| | ៤.២.៣.៤ បង្កើនវិធានការនានា ដើម្បីរឹតបន្តឹងរាល់ចរាចរសត្វឈឺ និងស្លាប់នៅក្នុងទូទាំងខេត្ត | ភាគរយនៃកសិករដែលអះអាងថាកប់ឬដុតសត្វឈឺ/ស្លាប់ដោយជំងឺ | X | X | X | X | X |
| | ៤.២.៣.៥ ហាមឃាត់តឹងរ៉ឹងចំពោះការចរាចរសត្វឈឺ និងងាប់នៅក្នុងខេត្ត | ទស្សនៈរបស់កសិករចំពោះសេវាកម្មបសុ | | X | X | X | X |
| | ៤.២.៣.៦ រៀបចំ និងបង្កើតទីកន្លែងប្រមូលផ្តុំសម្រាប់ការលក់ដូរសត្វនៅតាមសហគមន៍ | ចំនួនសហគមន៍ដែលមានកន្លែងលក់ដូរសត្វជាលក្ខណៈប្រមូលផ្តុំ | | X | X | X | X |
| **៤.៣ ជំរុញការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព និងការថែរក្សាទឹក នៅលើវាលស្រែ** | | | | | | | |
| ៤.៣.១ ជំរុញការថែរក្សា និងគ្រប់គ្រងទឹកនៅតាមវាលស្រែ សម្រាប់ជួយដល់សហគមន៍ងាយរងគ្រោះ | ៤.៣.១.១ សហការជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក្នុងការស្តារប្រព័ន្ធធារាសាស្ត្រ នៅក្នុងទូទាំងស្រុកទាំង ៨ | ចំនួនប្រព័ន្ធស្រោចស្រពកម្រិតទីពីរដែលបានស្តារឡើងវិញ | X | X | X | X | X |
| | ៤.៣.១.២ សហការជាមួយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត និងក្រុមប្រឹក្សាឃុំ ដើម្បីសាងសង់ប្រឡាយរងបង្ហូរទឹកចូលស្រែនៅក្នុង | ចំនួនប្រព័ន្ធស្រោចស្រពដែលបានកសាង | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ស្រុកចំនួន៥ | និងស្តារឡើងវិញ | | | | | |
| | ៤.៣.១.៣ លើកទឹកចិត្ត និងជំរុញប្រព័ន្ធដំណក់ទឹក នៅតំបន់ដែលប្រឈមនឹងគ្រោះរាំងស្ងួត | ចំនួនកសិករដែលអនុវត្តបច្ចេកទេស | X | X | X | X | X |
| | ៤.៣.១.៤ លើកទឹកចិត្ត និងជំរុញការរៀបចំថ្នាលសំណាបរួម និងថ្នាលដាប៉ុក នៅតំបន់ដែលប្រឈមនឹងគ្រោះរាំងស្ងួត | ចំនួនកសិករដែលអនុវត្តបច្ចេកទេស | X | X | X | X | X |
| ៤.៣.២ បង្កើនបច្ចេកទេសប្រមូលទឹក ផលិតកម្មទឹក និងការគ្រប់គ្រងគ្រោះរាំងស្ងួត នៅតំបន់ប្រឈមនឹងគ្រោះរាំងស្ងួត | ៤.៣.២.១ រៀបចំការសិក្សាពីប្រសិទ្ធភាពសេដ្ឋកិច្ច នៃប្រព័ន្ធទ្វារទឹក និងទំនប់កាត់តាមស្ទឹង នៅក្នុងស្រុកថ្ពង ស្រុកឱរ៉ាល់ ស្រុកភ្នំស្រួច ស្រុកបសេដ្ឋ និងស្រុកគងពិសី | លទ្ធផលនៃការសិក្សាត្រូវបានប្រើប្រាស់សម្រាប់ការសម្រេចចិត្ត | X | X | X | | |
| | ៤.៣.២.២ កសាងទ្វារទឹក និងទំនប់កាត់ទទឹងស្ទឹងចំនួន ៥ កន្លែង នៅឃុំអមលាំងក្នុងស្រុកថ្ពងនិងនៅក្នុងស្រុកឧដុង្គ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត នៅក្នុងតំបន់ | ចំនួនសំណង់ស្ទាក់ទឹកដែលបានកសាង | X | X | X | X | X |
| | ៤.៣.២.៣ លើកទឹកចិត្ត និងតម្លើងប្រព័ន្ធស្រោចស្រពតាមបំពង់ដោយប្រើប្រាស់ប្រភពទឹកពីភ្នំ ដែលគ្រប់គ្រងដោយសហគមន៍ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះរាំងស្ងួត នៅក្នុងស្រុកឱរ៉ាល់ ស្រុកភ្នំស្រួច ស្រុកថ្ពង ស្រុកបសេដ្ឋ និងស្រុកគងពិសី | ចំនួនប្រព័ន្ធស្រោចស្រពតាមបំពង់ដែលបានតម្លើង | X | X | X | X | X |
| | ៤.៣.២.៤ បង្កើនបច្ចេកទេសប្រមូលទឹក ដូចជាជីកស្រះជាលក្ខណៈគ្រួសារ កសាងអាងត្រងទឹកភ្លៀង នៅតំបន់ដែលខ្វះខាតប្រភពទឹក និងប្រភពទឹកក្រោមដីមានជាតិពុល | ចំនួនស្រះសហគមន៍ដែលបានកសាង | X | X | X | X | X |
| **៤.៤ ជំរុញយន្តការផ្ទេរហានិភ័យ** | | | | | | | |
| ៤.៤.១ ជំរុញ និងបង្កើតបន្ថែមសហគមន៍កសិកម្ម ធនាគារស្រូវ ធនាគារពូជ ធនាគារសត្វ | ៤.៤.១.១ ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីមន្ទីរកសិកម្ម និងការិយាល័យកសិកម្មស្រុក និងមន្ត្រីអង្គការមិនមែនរដ្ឋាភិបាល ស្តីពីច្បាប់បង្កើតសហគមន៍កសិកម្ម ធនាគារកសិកម្ម | ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំ | X | X | X | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| និងប្រព័ន្ធសុវត្ថិភាពសង្គម នៅតំបន់ដែលប្រឈមមុខនឹងគ្រោះមហន្តរាយ | ៤.៤.១.២ សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នជំនាញដទៃទៀត ដើម្បីរៀបចំសហគមន៍កសិកម្ម ធនាគារស្រូវ ធនាគារពូជ ធនាគារសត្វ។ល។ និងសាលារៀនស្រែកសិករ | ចំនួនសហគមន៍កសិករដែលបានបង្កើត | X | X | X | X | X |
| | ៤.៤.១.៣ ជំរុញការបង្កើនប្រសិទ្ធភាពនៃធនាគារពូជ និងប្រព័ន្ធថែរក្សាពូជនៅតាមសហគមន៍ | ភាគរយកសិករដែលបន្សុទ្ធ និងរក្សាទុកពូជដំណាំ | X | X | X | X | X |
| **៤.៥ កាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីការប្រើប្រាស់ជីនិងថ្នាំកសិកម្ម កម្រិតខេត្ត និងមូលដ្ឋាន** | | | | | | | |
| ៤.៥.១ ជំរុញការអនុវត្តច្បាប់ គតិយុទ្ធនានា និងការត្រួតពិនិត្យគុណភាពជី និងថ្នាំកសិកម្ម ដោយសហការយ៉ាងជិតស្និទជាមួយ ក.ស.ក | ៤.៥.១.១ អនុវត្តច្បាប់ ប្រកាស និងសារាចរណ៍ ទាក់ទងនឹងជី និងថ្នាំកសិកម្ម | ទស្សនៈរបស់កសិករចំពោះការអនុវត្តច្បាប់កសិកម្ម | X | X | X | X | X |
| | ៤.៥.១.២ រៀបចំអធិការកិច្ចជាប្រចាំទៅលើហាងលក់ដុំ និងរាយសាខាចែកចាយជី និងថ្នាំកសិកម្ម នៅទូទាំងខេត្ត ដើម្បីត្រួតពិនិត្យគុណភាព (កាលបរិច្ឆេទផុតកំណត់ សេចក្តីណែនាំពីការប្រើប្រាស់ស្លាកសញ្ញាជាអក្សរខ្មែរ) | ចំនួនអធិការកិច្ចប្រចាំខែដែលបានរៀបចំ | X | X | X | X | X |
| ៤.៥.២ បង្កើនសមត្ថភាព និងការយល់ដឹងដល់អ្នកលក់ និងអ្នកប្រើប្រាស់អំពីផលប៉ះពាល់របស់ជី និងថ្នាំកសិកម្ម | ៤.៥.២.១ បង្កើនបច្ចេកទេសដល់អ្នកលក់ ចែកចាយ និងកសិករអំពីបច្ចេកទេសនៃការប្រើប្រាស់ និងផលប៉ះពាល់របស់ជីនិងថ្នាំកសិកម្ម | ទស្សនៈរបស់កសិករចំពោះគុណភាពនៃសេវាកម្ម | X | X | X | X | X |
| | ៤.៥.២.២ បង្កើនយុទ្ធនាការនៃការយល់ដឹងជាសាធារណៈអំពីផលប៉ះពាល់របស់ជី និងថ្នាំកសិកម្ម | សមាមាត្រកសិករដែលយល់ដឹងពីផលប៉ះពាល់អវិជ្ជមាននៃថ្នាំកសិកម្ម | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **អាទិភាពទី ៥៖ ពង្រឹងសមត្ថភាពត្រៀមរៀបចំ និងឆ្លើយតបឲ្យមានប្រសិទ្ធភាព និងសមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការឆ្លើយយតបសង្គ្រោះបន្ទាន់ក្នុងវិស័យកសិកម្ម** | | | | | | | |
| **៥.១ ពង្រឹងសមត្ថភាពធនធានរបស់មន្ទីរកសិកម្មខេត្ត ក្នុងការរៀបចំផែនការត្រៀមបម្រុងជាប្រចាំ និងសមាហរណកម្មទៅក្នុងផែនការ និងសកម្មភាពដែលកំពុងដំណើរការ** | | | | | | | |
| ៥.១.១ ពង្រឹងសមត្ថភាពរបស់មន្ទីរ ក្នុងការឆ្លើយតបសង្គ្រោះបន្ទាន់ សម្រាប់វិស័យកសិកម្ម ឲ្យបានទាន់ពេលវេលា | ៥.១.១.១ កសាងផែនការត្រៀមបម្រុង ឲ្យស្របតាមផែនការឆ្លើយតបត្រៀមឆ្លើយតបសង្គ្រោះបន្ទាន់ របស់ថ្នាក់ជាតិ | ផែនការត្រៀមបម្រុងអាចរកបាន | | X | X | | |
| | ៥.១.១.២ រៀបចំលំហាត់ផែនការត្រៀមបម្រុង នៅក្នុងតំបន់ដែលប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ និងកំណត់ការអនុវត្តមួយចំនួន ដើម្បីការត្រៀមរៀបចំ និងការឆ្លើយតបសង្គ្រោះបន្ទាន់ | ចំនួនលំហាត់សមយុទ្ធដែលបានអនុវត្ត | | X | X | X | X |
| ៥.១.២ ពង្រឹងសមត្ថភាពក្នុងការបញ្ជ្រាប DRR និង CCA ទៅក្នុងគម្រោងត្រៀមរៀបចំ ឆ្លើយតប និងស្តារឡើងវិញ | ៥.១.២.១ បញ្ជ្រាប DRR និង CCA ទៅក្នុងរាល់គម្រោងត្រៀមរៀបចំ ឆ្លើយតប និងស្តារឡើងវិញនានា របស់មន្ទីរកសិកម្ម | សមាមាត្រគម្រោងដែលបានដាក់បញ្ចូល DRR និង CCA | X | X | X | X | X |
| | ៥.១.២.២ ផ្តល់នូវការគាំទ្របច្ចេកទេសដល់ឃុំមួយចំនួន ដើម្បីអាចបញ្ជ្រាបបច្ចេកទេសកសិកម្មធន់ និងបង្កុំបច្ចេកទេសកសិកម្ម ទៅក្នុងផែនការវិនិយោគ ផែនការអភិវឌ្ឍន៍ឃុំ | សមាមាត្រឃុំដែលបានបញ្ចូលបច្ចេកទេសកសិកម្មធន់ក្នុងផែនការ | X | X | X | X | X |
| **៥.២ បង្កើនប្រសិទ្ធភាពនៃសកម្មភាពឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញក្រោយគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម និងបញ្ចូលអន្តរាគមន៍ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងវិធានការស្តារឡើងវិញ និងកសាងឡើងវិញ** | | | | | | | |
| ៥.២.១ ជំរុញការត្រៀមបម្រុងធនធានកសិកម្ម នៅកម្រិតមន្ទីរ និងកម្រិតគ្រួសារសម្រាប់ការឆ្លើយតបសង្គ្រោះបន្ទាន់ | ៥.២.១.១ ជំរុញការត្រៀមបម្រុងនៅកម្រិតមន្ទីរ និងកម្រិតគ្រួសារនូវពូជស្រូវសុទ្ធ និងមានគុណភាពល្អ មិនប្រកាន់រដូវ រយៈពេលខ្លី (ខាពសម្រាប់គ្រោះរាំងស្ងួត សែនពិដោរ ជលសារ អុីអ៊ែ៦៦ រំដួល រមៀត រំដេង ច័ន្ទសែនស) សម្រាប់ការស្តារឡើងវិញបន្ទាប់ពីគ្រោះទឹក | បរិមាណពូជស្រូវត្រៀមបម្រុងនៅកម្រិតខេត្ត | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| និងការស្តារឡើងវិញ | ជំនន់ និងគ្រោះរាំងស្ងួត | | | | | | |
| | ៥.២.១.២ ជំរុញការត្រៀមបម្រុងនៅកម្រិតមន្ទីរ និងកម្រិតគ្រួសារនូវពូជបន្លែសមស្រប សម្រាប់ការស្តារឡើងវិញបន្ទាប់ពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត | បរិមាណពូជបន្លែត្រៀមបម្រុងនៅកម្រិតខេត្ត | X | X | X | X | X |
| | ៥.២.១.៣ ត្រៀមថ្នាំកម្ចាត់សត្វល្អិត ជាពិសេស មមាចត្នោត និងកណ្តូប និងត្រៀមរៀបចំសម្រាប់ការឆ្លើយតបបន្ទាន់នៅកម្រិតខេត្ត | បរិមាណថ្នាំកសិកម្មត្រៀមបម្រុងនៅកម្រិតខេត្ត | X | X | X | X | X |
| | ៥.២.១.៤ ត្រៀមប្រេងម៉ាស៊ីនបូមទឹកនៅថ្នាក់ខេត្ត ក្នុងការជួយសង្គ្រោះក្នុងពេលគ្រោះរាំងស្ងួត | បរិមាណប្រេងដែលត្រៀមទុកសម្រាប់សង្គ្រោះបន្ទាន់ | X | X | X | X | X |
| | ៥.២.១.៥ ត្រៀមវ៉ាក់សាំងគោ/ក្របីនៅថ្នាក់ខេត្តសម្រាប់បង្ការជំងឺសារទឹក បូសខ្យល់ អុតក្តាម មុនពេលផ្ទុះជំងឺ (នៅកំឡុងខែ ឧសភា និងកញ្ញា) | បរិមាណដូសវ៉ាក់សាំងដែលបានត្រៀមបម្រុងនៅកម្រិតខេត្ត | X | X | X | X | X |
| | ៥.២.១.៦ លើកទឹកចិត្តឲ្យកសិកររក្សាស្មៅ/ចំបើងសម្រាប់គោ ក្របីដោយទុកដាក់ឲ្យផុតពីទឹក សម្រាប់ពេលមានគ្រោះទឹកជំនន់/រាំងស្ងួត | សមាមាត្រកសិករដែលត្រៀមស្មៅ ចំបើងសម្រាប់សត្វ | X | X | X | X | X |
| | ៥.២.១.៧ កំណត់ទីតាំង/កសាងទីទួលសុវត្ថភាពដោយបំពាក់សម្ភារចាំបាច់មួយចំនួន សម្រាប់គោ ក្របី ក្នុងកំឡុងពេលមានទឹកជំនន់ | ផែនទីទីទួលសុវត្ថិភាពអាចរកបាន | X | X | X | | |
| ៥.២.២ ជំរុញ និងពង្រឹងវិធានការសម្រាប់ស្ថានភាពគ្រោះអាសន្ន នៅក្នុងវិស័យកសិកម្ម | ៥.២.២.១ កសាងសមត្ថភាពដល់ក្រុមបសុពេទ្យ បំពាក់ឧបករណ៍ចាំបាច់នានា និងត្រៀមសម្រាប់ការចុះអន្តរាគមន៍ចាក់វ៉ាក់សាំងព្យាបាលគោ ក្របី ដោយសហការណ៍ជាមួយក្រុមការងារថ្នាក់ជាតិ និងថ្នាក់ខេត្ត | ទស្សនៈរបស់កសិករចំពោះប្រសិទ្ធភាពនៃការឆ្លើយតបសង្គ្រោះបន្ទាន់ | X | X | X | X | X |
| | ៥.២.២.២ បង្កើត និងកសាងសមត្ថភាពក្រុមចុះវាយតម្លៃ និងប៉ាន់ | ទស្សនៈរបស់កសិករ | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រមាណផលប៉ះពាល់តាមវិស័យនៃគ្រោះមហន្តរាយ ដោយសហការជាមួយក្រុមការងារថ្នាក់ជាតិ (ក.ស.ក និងគ.ជ.គ.ម) និងស្ថាប័នពាក់ព័ន្ធផ្សេងៗ | ចំពោះប្រសិទ្ធភាពនៃការឆ្លើយតបសង្គ្រោះបន្ទាន់ | | | | | |
| | ៥.២.២.៣ លើកទឹកចិត្តក្នុងការធ្វើវិភាជន៍ និងគ្រប់គ្រងមូលនិធិសម្រាប់ការឆ្លើយតប និងការស្តារឡើងវិញ នៅក្នុងវិស័យកសិកម្ម និងសាកល្បងនៅក្នុងស្រុកចំនួន ៣ ដែលប្រឈមនឹងគ្រោះរាំងស្ងួត និងសមាសភាគចង្រៃនិងជំងឺ | ចំនួនឃុំដែលមានថវិកាបម្រុងសម្រាប់ត្រៀមឆ្លើយតបសង្គ្រោះបន្ទាន់ | X | X | X | X | X |

## ឧបសម្ព័ន្ធទី ២ ៖ សកម្មភាពអាទិភាព សម្រាប់ឆ្នាំ ២០១៤-២០១៨

| គោលបំណង | សកម្មភាពជាក់លាក់ | ទីកន្លែង | ឆ្នាំនៃការអនុវត្ត | | | | | ថវិកា (ដុល្លា) | ស្ថាប័ន |
|---|---|---|---|---|---|---|---|---|---|
| | | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | | |
| កសិករដែលមានដីស្រែ ចំការតូចៗអាចទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ | លើកទឹកចិត្ត និងជំរុញគោលការណ៍សួនពហុចម្រុះ ទៅដល់កសិករខ្នាតតូច ដើម្បីអាចកសាងភាពធន់នឹងគ្រោះរាំងស្ងួត | ស្រុកទាំង ៨ | X | X | X | X | X | ១២៣,៥០០ | មន្ទីរកសិកម្មខេត្ត |
| កសិករតូចតាច និងមធ្យមអាចបង្កើនផលិតភាព និងផលិតកម្មសត្វ | រៀបចំការប៉ាន់ប្រមាណហានិភ័យ និងផែនទីមុខសញ្ញាគ្រោះថ្នាក់និងភាពងាយរងគ្រោះ សម្រាប់ផលិតកម្មសត្វ ជាពិសេសជ្រូក និងផលិតបក្សី និងប្រើប្រាស់ជាឧបករណ៍ជំនួយស្មារតីសម្រាប់កសិកម្មខ្នាតតូច និងមធ្យម | ស្រុកសំរោងទង គងពិសី បសេដ្ឋ ច្បារមន និងភ្នំស្រួច | | X | X | X | | ១១៤,000 | ការិ. ផលិតកម្ម និងបសុព្យាបាល |
| កសិករទទួលបានទឹកគ្រប់គ្រាន់សម្រាប់បង្កើនផលិតផលកសិកម្ម | កសាងទ្វារទឹក និងទំនប់កាត់ទទឹងស្ទឹងចំនួន ៥ កន្លែង ដើម្បីកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត | ស្រុកថ្ពង ស្រុកឧដុង្គ | X | X | X | X | X | ១៩៩,000 | មន្ទីកសិកម្មខេត្ត |
| ក្រុមប្រឹក្សាឃុំឆ្លើយតបដោយមានប្រសិទ្ធភាពចំពោះតម្រូវការបច្ចេកទេសកសិកម្មរបស់កសិករ ដែលអាចកសាងភាពធន់នឹងគ្រោះមហន្តរាយនិងអាចដាក់បញ្ចូល DRR និង CCA ទៅក្នុងផែនការឃុំ | ផ្តល់ការគាំទ្របច្ចេកទេសដល់ឃុំមួយចំនួន ដើម្បីអាចបញ្ជ្រាបបច្ចេកទេសកសិកម្មធន់ និងបង្កុំបច្ចេកទេសកសិកម្ម ទៅក្នុងផែនការវិនិយោគនិងផែនការអភិវឌ្ឍន៍ឃុំ | ស្រុកបសេដ្ឋ ស្រុកឧដុង្គ | X | X | X | X | X | ៥0,000 | ការិយាល័យផ្សព្វផ្សាយកសិកម្ម |
| កសិករតូចតាចទទួលបានឱកាសសម្រាប់ការបង្កបង្កើនផល | លើកទឹកចិត្ត និងជំរុញការរៀបចំថ្នាលសំណាបរួម និងថ្នាលដាប៉ុក នៅតំបន់ដែលប្រឈមនឹងគ្រោះរាំងស្ងួត | ស្រុកបសេដ្ឋ គងពិសី ថ្ពង សំរោងទង | X | X | X | X | X | ៣៦,000 | ការិ.ក្សេត្រសាស្ត្រ |

# ឧបសម្ព័ន្ធទី ៣ ៖ តារាងសង្ខេបនៃផែនការសកម្មភាព

គោលដៅ៖ ដើម្បីពង្រឹងសមត្ថភាពនិងកសាងភាពធន់របស់កសិករ និងសហគមន៍ទៅនឹងការគំរាមកំហែងពីគ្រោះមហន្តរាយដែលប៉ះពាល់ដល់វិស័យកសិកម្មនិងជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ

**លទ្ធផលរំពឹងទុក**

- វិធានការ DRR និង CCA ត្រូវបានដាក់បញ្ចូលទៅក្នុងរាល់ផែនការ សកម្មភាព និងកម្មវិធីតាមវិស័យ និងអនុវិស័យនានារបស់មន្ទីរកសិកម្ម
- កសិករបង្កើនការទទួលបាន និងការប្រើប្រាស់ EWS ព័ត៌មានកសិឧតុនិយមសម្រាប់ធ្វើការសម្រេចចិត្ត តាមរយៈប្រក្រតិទិនដាំដុះប្រចាំឆ្នាំ
- ជម្រើសបច្ចេកទេសល្អៗដើម្បីបង្កើនភាពធន់ក្នុងវិស័យកសិកម្ម អាចរកបាន និងត្រូវបានអនុវត្តដោយកសិករ និងចែករំលែកយ៉ាងទូលំទូលាយ
- អ្នកធ្វើផែនការ អ្នកផ្សព្វផ្សាយថ្នាក់ក្រោមជាតិ ត្រូវបានបណ្តុះបណ្តាល ដើម្បីជំរុញយ៉ាងសកម្ម នូវបច្ចេកទេសកសិកម្មសមស្របតាមតំបន់ ដើម្បីបង្កើនភាពធន់
- កសិករត្រៀមរៀបចំ ដើម្បីដោះស្រាយមុខសញ្ញាគ្រោះថ្នាក់ និងទទួលបានជំនួយសង្គ្រោះបន្ទាន់បានទាន់ពេលវេលា ក្នុងករណីដែលមានការប្រកាសគ្រោះអាសន្ន

**ក្របខ័ណ្ឌសកម្មភាពការងារជាអាទិភាព**

| ពង្រឹងសមត្ថភាពស្ថាប័ននិងបច្ចេកទេស និងបង្កើនយន្តការសម្របសម្រួលសម្រាប់ DRR និង CCA ក្នុងវិស័យកសិកម្ម | ជំរុញ និងពង្រឹង EWSសម្រាប់ DRR និង CCA ដោយភាពសកម្ម | ពង្រឹងការគ្រប់គ្រងចំណេះដឹង និងគំនិតផ្តួចផ្តើមថ្មី ក្នុងការគាំទ្រដល់ DRR និង CCA ក្នុងវិស័យកសិកម្ម | កាត់បន្ថយភាពងាយរងគ្រោះតាមរយៈការបង្កើនជម្រើសបច្ចេកទេសក្នុងវិស័យកសិកម្ម និងការលើកកំពស់ដំណើរការនៃ CBDRR និង CCA | ពង្រឹងសមត្ថភាពត្រៀមរៀបចំ និងឆ្លើយតបឲ្យមានប្រសិទ្ធភាព និងសមាហរណកម្មការ DRR និង CCA ទៅក្នុងការឆ្លើយយតបសង្គ្រោះបន្ទាន់ក្នុងវិស័យកសិកម្ម |
|---|---|---|---|---|
| - ពង្រឹងយន្តការស្ថាប័នសម្រាប់ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងស្ថាប័នជំនាញ និងអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្ត សម្រាប់ការអនុវត្ត DRR និង CCA<br>- ពង្រឹងសមត្ថភាពស្ថាប័នរបស់មន្ទីរកសិកម្ម និងការិយាល័យកសិកម្មស្រុក សម្រាប់ការអនុវត្ត DRR និង CCA ប្រកបដោយប្រសិទ្ធភាព | - ជំរុញ និងគាំទ្រការផ្លាស់ប្តូរទិន្នន័យសម្រាប់សេវាកម្មអាកាសធាតុ និង EWS ក្នុងវិស័យកសិកម្ម ជាមួយមន្ទីរ និងអ្នកពាក់ព័ន្ធនានា<br>- ជំរុញការផលិតព័ត៌មាន EW ជាក់លាក់ ដែលកែសម្រួលទៅតាមតម្រូវការក្នុងវិស័យកសិកម្ម<br>- ពង្រឹងបណ្តាញទំនាក់ទំនងសម្រាប់ការផ្សព្វផ្សាយព័ត៌មានទៅដល់កសិករ និងសហគមន៍អាស្រ័យលើកសិកម្ម | - ពង្រឹង និងឬភ្ជាប់ទិន្នន័យទាក់ទងនឹង DRR និង CCA ដើម្បីរៀបចំផែនការ និងការសម្រេចចិត្តឲ្យកាន់តែប្រសើរឡើង<br>- បង្កើនមូលដ្ឋាន ចំណេះដឹង និងជំរុញគំនិតផ្តួចផ្តើមថ្មីសម្រាប់ DRR និង CCA ក្នុងវិស័យកសិកម្ម ដោយរួមបញ្ចូលការចងក្រងនិងផ្សព្វផ្សាយបច្ចេកទេសល្អៗ<br>- បង្កើនការយល់ដឹង និងទំនាក់ទំនងសម្រាប់ការ DRR និង CCA ក្នុងវិស័យកសិកម្ម | - ជំរុញប្រព័ន្ធកសិកម្មចម្រុះ និងពិពិធកម្មដំណាំ ដើម្បីកសាងភាពធន់របស់សហគមន៍កសិកម្មទៅនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយ<br>- បង្កើនផលិតកម្មសត្វនៅគ្រប់កម្រិត<br>- ជំរុញការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព និងការថែរក្សាទឹក នៅលើវាលស្រែ<br>- ជំរុញយន្តការផ្ទេរហានិភ័យ<br>- កាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីការប្រើប្រាស់ជីនិងថ្នាំកសិកម្ម កម្រិតខេត្ត និងមូលដ្ឋាន | - ពង្រឹងសមត្ថភាពធនធានរបស់មន្ទីរកសិកម្មខេត្ត ក្នុងការរៀបចំផែនការត្រៀមបម្រុងជាប្រចាំ និងសមាហរណកម្មទៅក្នុងផែនការ និងសកម្មភាពដែលកំពុងដំណើរការ<br>- បង្កើនប្រសិទ្ធភាពនៃសកម្មភាពឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញក្រោយគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម និងបញ្ចូលអន្តរាគមន៍ DRR ទៅក្នុងវិធានការស្តារឡើងវិញ និងកសាងឡើងវិញ |

**បញ្ហាអន្តរវិស័យ**

| ការកសាងសមត្ថភាព | ភាពជាដៃគូ | សមធម៌យេនឌ័រ |
|---|---|---|

## ឧបសម្ព័ន្ធទី៤៖ និយមន័យ

**ការបន្សាំ** ៖ មានន័យថាការកែតម្រូវនៅក្នុងប្រព័ន្ធធម្មជាតិ ឬ ប្រព័ន្ធមនុស្ស ដើម្បីឆ្លើយតបនឹងកត្តាជំរុញអាកាសធាតុជាក់ស្តែង ឬ រំពឹងទុក ឬ ផលប៉ះពាល់អាកាសធាតុ ដែលបន្ថយគ្រោះថ្នាក់ និងទទួលបានឱកាសដែលមានអត្ថប្រយោជន៍។

**ការប្រែប្រួលអាកាសធាតុ** ៖ ការប្រែប្រួលដែលសង្កេតឃើញនៅក្នុងអាកាសធាតុ កម្រិតសកល តំបន់ ឬអនុតំបន់ បណ្តាលមកពីដំណើរការធម្មជាតិ និង/ឬ សកម្មភាពមនុស្ស។ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាការកែតម្រូវនៅក្នុងប្រព័ន្ធធម្មជាតិ ឬ ប្រព័ន្ធមនុស្ស ដើម្បីឆ្លើយតបនឹងកត្តាជំរុញអាកាសធាតុជាក់ស្តែង ឬ រំពឹងទុក ឬ ផលប៉ះពាល់អាកាសធាតុ ដែលបន្ថយគ្រោះថ្នាក់ និងទទួលបានឱកាសដែលមានអត្ថប្រយោជន៍។

**គ្រោះមហន្តរាយ** ៖ ការរំខានដ៏ធ្ងន់ធ្ងរនៃដំណើរការប្រព្រឹត្តទៅរបស់សហគមន៍ ឬ សង្គម បណ្តាលឲ្យមានការបាត់បង់ជីវិតមនុស្ស សម្ភារ សេដ្ឋកិច្ច ឬ បរិស្ថាន ដែលលើសពីសមត្ថភាពរបស់សហគមន៍សង្គមដែលរងផលប៉ះពាល់ ក្នុងការដោះស្រាយ ដោយប្រើប្រាស់ធនធានផ្ទាល់ខ្លួនតែម៉្យាង។ ជារឿយៗ គ្រោះមហន្តរាយត្រូវបានចាត់ជាប្រភេទស្របទៅតាមមូលហេតុរបស់វា (គ្រោះមហន្តរាយធម្មជាតិ ឬ បង្កឡើងដោយមនុស្ស)។

**ការគ្រប់គ្រង និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ** ៖ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយគឺជាការបន្តនៃដំណើរការ និងវិធានការទាក់ទងនឹងការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ ការត្រៀមរៀបចំ ការឆ្លើយតបសង្គ្រោះបន្ទាន់ ការស្តារឡើងវិញ និងការកសាងឡើងវិញ។ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺជាសំណុំរងនៃសមត្ថភាពអភិវឌ្ឍន៍ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងការលើកកម្ពស់គោលការណ៍ ដំណើរការ និងវិធានការដែលផ្តោតលើ ការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំឲ្យកាន់តែប្រសើរសម្រាប់ការឆ្លើយតប។

១. **ការត្រៀមបង្ការ** ៖ វិធានការដែលត្រូវបានអនុវត្តក្នុងគោលបំណងបង្ការបាតុភូតដែលបង្កើតឡើងដោយធម្មជាតិ ឬ មនុស្ស ដើម្បីជៀសវាងការកើតឡើង ឬ កើនឡើងនូវគ្រោះមហន្តរាយ ឬស្ថានភាពគ្រោះអាសន្នផ្សេងទៀត។

២. **ការកាត់បន្ថយគ្រោះថ្នាក់** ៖ វិធានការដែលត្រូវបានអនុវត្តដើម្បីកាត់បន្ថយការបាត់បង់ជីវិត ជីវភាពរស់នៅ និងទ្រព្យសម្បត្តិ ដោយសារគ្រោះមហន្តរាយ តាមរយៈការកាត់បន្ថយភាពងាយរងគ្រោះ ឬ តាមរយៈការផ្លាស់ប្តូរមុខសញ្ញាគ្រោះថ្នាក់ ក្នុងករណី ដែលអាចធ្វើទៅបាន។

**៣. ការត្រៀមរៀបចំ ៖** វិធានការដែលត្រូវបានអនុវត្តដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ តាមរយៈការរៀបចំប្រព័ន្ធជាមុន ដើម្បីឆ្លើយតបភ្លាមៗ និងមានប្រសិទ្ធភាព។ ការត្រៀមរៀបចំធ្វើសកម្មភាពទាំងក្នុង ដំណាក់កាលមុនគ្រោះមហន្តរាយ ឧទាហរណ៍ ការប្រកាសឲ្យដឹងមុន និងការជម្លៀស ព្រមទាំងដំណាក់កាលក្រោយគ្រោះមហន្តរាយ។

**៤. ការឆ្លើយតប ៖** សកម្មភាពដែលត្រូវបានអនុវត្តនៅក្នុងស្ថានភាពគ្រោះមហន្តរាយ ក្នុងគោលបំណងសង្គ្រោះជីវិត សម្រាលទុក្ខវេទនា និងកាត់បន្ថយការខាតបង់សេដ្ឋកិច្ច។

**៥. ការស្តារឡើងវិញ ៖** ការជួសជុលរយៈពេលខ្លីទៅលើការខូចខាតផ្នែករូបសាស្ត្រ សង្គម និងសេដ្ឋកិច្ច ដែលគ្រប់គ្រាន់ល្មមសម្រាប់ការវិលត្រឡប់ទៅគាំទ្រខ្លួនឯងវិញបាន។

**៦. ការកសាងឡើងវិញ ៖** ការជួសជុលរយៈពេលមធ្យមនិងរយៈវែង ចំពោះការខូចខាតផ្នែករូបសាស្ត្រ សង្គម និងសេដ្ឋកិច្ច និង ការទទួលបានមកវិញនូវរចនាសម្ព័ន្ធដែលទទួលរងផលប៉ះពាល់មកត្រឹមលក្ខខណ្ឌដែលស្មើ ឬ ប្រសើរជាងមុនពេលមានគ្រោះមហន្តរាយ។

**ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ៖** ដំណើរការជាប្រព័ន្ធនៃការប្រើប្រាស់ការសម្រេចចិត្តរដ្ឋបាល ការរៀបចំ ជំនាញនិងសមត្ថភាពប្រតិបត្តិការ ដើម្បីអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសមត្ថភាពដោះស្រាយរបស់សង្គម និងសហគមន៍ ដើម្បីបន្ថយផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ និងគ្រោះមហន្តរាយពីបរិស្ថាន និងបច្ចេកវិទ្យាដែលពាក់ព័ន្ធ។ ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនេះ រួមមានសកម្មភាពគ្រប់ទម្រង់ទាំងអស់ ដោយរាប់បញ្ចូលវិធានការជារចនាសម្ព័ន្ធ និងមិនមែនជារចនាសម្ព័ន្ធ ដើម្បីជៀសវាង (ការត្រៀមបង្ការ) ឬ រឹតបន្តឹង (ការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំ) ទៅលើឥទ្ធិពលអវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់ (*UN ISDR*)។

**ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ៖** សកម្មភាពដើម្បីកាត់បន្ថយឲ្យបានជាអតិបរមាចំពោះភាពងាយរងគ្រោះ និងហានិភ័យគ្រោះមហន្តរាយនៅក្នុងសង្គម ដើម្បីជៀសវាង (ការត្រៀមបង្ការ) ឬ រឹតបន្តឹង (ការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំ) ទៅលើឥទ្ធិពលអវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់ នៅក្នុងបរិបទទូលំទូលាយនៃការអភិវឌ្ឍន៍ ប្រកបដោយចីរភាព។ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយមានពាក់ព័ន្ធទៅនឹង៖ (១) ការយល់ដឹង និងការប៉ាន់ប្រមាណអំពីហានិភ័យ (២) ការអភិវឌ្ឍចំណេះដឹង (៣) ការប្តេជ្ញាចិត្តជាសាធារណៈ និងក្របខ័ណ្ឌស្ថាប័ន (៤) ការអនុវត្តពហុវិធានការ (៥) ប្រព័ន្ធប្រកាសឲ្យដឹងមុន វិធានការត្រៀមរៀបចំ និងសមត្ថភាពឆ្លើយតប (*UNISDR*)។

**មុខសញ្ញាគ្រោះថ្នាក់ ៖** ហេតុការណ៍ជារូបវ័ន្តដែលអាចបង្កឲ្យមានការខូចខាតជាសក្តានុពល បាតុភូត និង/ឬ សកម្មភាពមនុស្ស ដែលអាចបង្កឲ្យបាត់បង់អាយុជីវិត ឬ រងរបួស ខូចខាតទ្រព្យសម្បត្តិ រំខានដល់សង្គម និងសេដ្ឋកិច្ច ឬ ខូចខាតបរិស្ថាន។

**មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ៖** ដំណើរការ ឬ បាតុភូតធម្មជាតិ ដែលកើតឡើងនៅក្នុងដែនជីវៈ ដែលអាចរួមចំណែកឲ្យមានហេតុការណ៍មួយដែលបង្កការខូចខាត។

**ហានិភ័យ ៖** លទ្ធភាពនៃផលវិបាកដែលអាចបង្កជាគ្រោះថ្នាក់ ឬ ការបាត់បង់ដែលគេរំពឹងទុក (ជីវិត រងរបួស ទ្រព្យសម្បត្តិ ជីវភាព សកម្មភាពសេដ្ឋកិច្ចដែលបានទទួលរងការរំខាន ឬ ការខូចខាតបរិស្ថាន) ដែលបណ្ដាលពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់បង្កឡើងដោយធម្មជាតិ ឬ មនុស្ស និងលក្ខខណ្ឌងាយរងគ្រោះនានា។ ជាទូទៅ ហានិភ័យត្រូវបានបង្ហាញដោយសមីការះ

ហានិភ័យ = មុខសញ្ញាគ្រោះថ្នាក់ *x* ភាពងាយរងគ្រោះ (*UN ISDR*)។

**កសិកម្មធន់ ៖** ជាដំណើរការ និងរបៀបនៃការអនុវត្តបច្ចេកទេសកសិកម្ម ដែលអាចធ្វើឲ្យប្រព័ន្ធកសិកម្មដំណើរការ និងទទួលបាននូវប្រព័ន្ធស្បៀងអាហារ។ កសិកម្មធន់ កាត់បន្ថយនូវការប្រែប្រួលប្រព័ន្ធសន្តិសុខស្បៀង ដែលមានលក្ខណៈវិលជុំ រ៉ាំរ៉ៃ ប្រកាន់រដូវ និងធ្ងន់ធ្ងរ (*បណ្ឌិត ហ្សង់ឆាលស៍ ឡឺវ៉ាល់ទ្បេ*)។

**យុទ្ធសាស្ត្រ ៖** គឺជាផែនការសកម្មភាពទូលំទូលាយ ដែលត្រូវបានអនុវត្តតាមរយៈគោលនយោបាយ និងវិធានការនានា។ យុទ្ធសាស្ត្រអាចមានលក្ខណៈទូលំទូលាយ (ឧ. ផ្ដោតលើកម្រិតថ្នាក់ជាតិ និងអន្តរវិស័យ) ឬកំណត់ទៅតាមគោលដៅ (ឧ. ផ្ដោតលើវិស័យ តំបន់ឬ វិធានការជាក់លាក់ណាមួយ)។

**ការអភិវឌ្ឍប្រកបដោយចីរភាព ៖** ការអភិវឌ្ឍដែលស្របតាមសេចក្ដីត្រូវការបច្ចុប្បន្ន ដោយមិនកាត់បន្ថយគ្រោះថ្នាក់ដោយសារតែលទ្ធភាពរបស់មនុស្សជំនាន់ក្រោយ ដែលអាចបំពេញតម្រូវការរបស់ពួកគេ។

**ភាពមិនច្បាស់លាស់ ៖** គឺជាការបង្ហាញអំពីកម្រិតតម្លៃមួយ (ឧ. លក្ខខណ្ឌនៃប្រព័ន្ធអាកាសធាតុនៅពេលអនាគត) ដែលគេមិនដឹង។

**ភាពងាយរងគ្រោះ ៖** កម្រងលក្ខខណ្ឌ និងដំណើរការ ដែលទទួលបានពីកត្តារូបសាស្ត្រ សង្គម សេដ្ឋកិច្ច និង បរិស្ថាន ដែលបង្កើនការប្រឈមរបស់សហគមន៍ទៅនឹងផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់។

## ឧបសម្ព័ន្ធទី៥៖ ក្របខ័ណ្ឌសកម្មភាពការងារយោហ្គោ ២០០៥-២០១៥

ក្របខ័ណ្ឌសកម្មភាពការងារយោហ្គោ ឆ្នាំ ២០០៥-២០១៥ គឺជាយុទ្ធសាស្ត្រព្រមព្រៀងមួយដែលត្រូវបានអនុម័តដោយប្រទេសជាសមាជិកចំនួន ១៦៨ នៅក្នុងសន្និសិទពិភពលោករបស់អង្គការសហប្រជាជាតិ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅខែ មករា ឆ្នាំ២០០៥ ក្នុងទីក្រុងកូបេ ខេត្តយោហ្គោ ប្រទេសជប៉ុន ដើម្បីដឹកនាំការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយជាសកល។ ក្របខ័ណ្ឌសកម្មភាពការងារយោហ្គោ២០០៥-២០១៥ត្រូវបានអភិវឌ្ឍផ្អែកលើការវិភាគអំពីចន្លោះប្រហោងនៅក្នុងកិច្ចខិតខំថ្នាក់ជាតិនិងសកល ក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងទសវត្សរ៍មុន ពីឆ្នាំ ១៩៩៤-២០០៤។

គោលដៅដែលត្រូវបានកំណត់ដោយ ក្របខ័ណ្ឌសកម្មភាពការងារយោហ្គោ ២០០៥-២០១៥ រួមមាន៖ ក) សមាហរណកម្មនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍ប្រកបដោយចីរភាព ខ) ការអភិវឌ្ឍ និងការពង្រឹងស្ថាប័ន យន្តការ និងសមត្ថភាពដើម្បីបង្កើនភាពធន់នឹងមុខសញ្ញាគ្រោះថ្នាក់ និង គ) ការរួមបញ្ចូលជាប្រព័ន្ធនៃវិធីសាស្ត្រកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងការអនុវត្តន៍កម្មវិធីត្រៀមរៀបចំ ឆ្លើយតប និងស្តារឡើងវិញពេលមានគ្រោះអាសន្ន។ ក្របខ័ណ្ឌសកម្មភាពការងារយោហ្គោ ២០០៥-២០១៥ ផ្តល់អនុសាសន៍នូវសកម្មភាពជាអាទិភាពចំនួនប្រាំ៖

- សកម្មភាពជាអាទិភាពទី ១៖ ធានាថាការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ គឺជាអាទិភាពនៅកម្រិតថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដោយមានមូលដ្ឋានស្ថាប័នរឹងមាំសម្រាប់ការអនុវត្ត។
- សកម្មភាពជាអាទិភាពទី២៖ កំណត់ ប៉ាន់ប្រមាណ និងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងបង្កើនការប្រកាសឲ្យដឹងមុន។
- សកម្មភាពជាអាទិភាពទី៣ ៖ ប្រើប្រាស់ចំណេះដឹង ការច្នៃប្រឌិត និង ការអប់រំ ដើម្បីបង្កើតវប្បធម៌សុវត្ថិភាព និងភាពធន់នៅគ្រប់កម្រិត។
- សកម្មភាពជាអាទិភាពទី ៤៖ កាត់បន្ថយដើមហេតុនៃកត្តាបង្កហានិភ័យ
- សកម្មភាពជាអាទិភាពទី៥៖ ពង្រឹងការត្រៀមរៀបចំដើម្បីឆ្លើយតបគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។

ប្រទេសកម្ពុជា បានបង្ហាញនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមរយៈការចុះហត្ថលេខាលើក្របខ័ណ្ឌសកម្មភាពការងារយោហ្គោ ឆ្នាំ២០០៥-២០១៥។ ប្រទេសកម្ពុជាបានរៀបចំផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រ សម្រាប់ការកាត់បន្ថយ

ហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០០៨-២០១៣ និងបន្តរៀបចំផែនការសកម្មភាពជាតិ សម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ២០១៤-២០១៨ ព្រមទាំងបានគូសបញ្ជាក់អំពីយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយរួចរាល់ផងដែរ។

# ឧបសម្ព័ន្ធទី៦ ៖ ក្រុមការងារសម្របសម្រួល និងរៀបចំផែនការ

| លេខ | នាម និងគោត្តនាម | តួនាទី | ស្ថាប័ន |
|---|---|---|---|
| ០១ | លោក សយ បញ្ញា | ប្រធានមន្ទីរ | មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ០២ | លោក ទៀង ហ៊ីល្លីណា | ប្រធានការិយាល័យក្សេត្រសាស្ត្រ | មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ០៣ | លោក ជិន អឿង | អនុប្រធានការិយាល័យផែនការ | មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ០៤ | លោកស្រី ជា ដានី | អនុប្រធានការិយាល័យក្សេត្រសាស្ត្រ | មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ០៥ | លោក ជា ហុកលី | មន្ត្រីការិយាល័យក្សេត្រសាស្ត្រ | មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ០៦ | លោក ឡឹក សុធារ | ទីប្រឹក្សាបច្ចេកទេស | អង្គការស្បៀងនិងកសិកម្ម នៃសហប្រជាជាតិ |

# ឯកសារយោង


1. Cambodian Agriculture Research and Development Institute (CARDI). 2013. Golden Apple Snail and Management, Farmer Notes, Cambodian Agriculture Research and Development Institute (CARDI), July 2013.\
2. Cambodian Center for Study and Development in Agriculture (CEDAC).2005. *Assessment of local authorities and communities practices and information needs to face disasters Report from surveys in Ba Phnom and Peam Ro districts, Prey Veng province, Cambodia*. Working Paper.Nov. 2005.
3. Climate Change Adaptation and Disaster Risk Management in Agriculture, Ministry of Agriculture and Cooperatives, Government of Nepal. 2011. *Priority framework for action 2011-2020*. April 2011.
4. FAO/WFP. 2012. *Crop and Food Security, Update Mission to Cambodia Report, , 17 April 2012.* http://documents.wfp.org/stellent/groups/public/documents/ena/wfp247059.pdf
5. FAO/ICP. 2007. *Final Report on IPM for Vegetables and TCP/310/CMB*..
6. Mekong River Commission. 2011. *Flood Situation Report 2011.* MRC Technical Paper , No 36., Nov. 2011. http://www.mrcmekong.org/assets/Publications/technical/Tech-No36-Flood-Situation-Report2011.pdf
7. Ministry of Agriculture, Forestry, and Fisheries (MAFF). 2012. *Roles of sustainable land management, Complement agreement in Agriculture in Cambodia*.
8. National Committee for Disaster Management (NCDM). 2013. *Flood Assessment Report*, December 2013.
9. National Committee for Disaster Management (NCDM). 2010. *Post Ketsana Disaster Needs Assessment, Part I: Main Report.* March 2010.
10. National Committee for Disaster Management and Ministry of Planning, Royal Government of Cambodia. 2008. *Strategic National Action Plan on Disaster Risk Reduction 2008-2013*.
11. Nobleman, M. T.2003. *Cambodia*. Mankato, Minn: Bridgestone Books. p. 7. ISBN 9780736813709.
12. Wikipedia, http://en.wikipedia.org/wiki/List_of_countries_by_Human_Development_Index
13. Provincial Department of Agriculture of Kampong Speu. 2013. Annual Report
14. Provincial Committee for Disaster Manager. 2013. Plan of Action for DRR of Kampong Speu, 2012-2014